# ការអនុវត្តដោយបង្ខំ
# (ការលក់ដោយបង្ខំនូវអចលនវត្ថុ)



ក្រសួងយុត្តិធម វិទ្យាស្ថានចម្រុះស្រាវជ្រាវនិងបណ្តុះបណ្តាលកិច្ចការច្បាប់ (ICD)
សាស្ត្រាចារ្យ HIGASHIO  Kazuyuki និងសាស្ត្រាចារ្យ YUKAWA  Ryo

*បានឈ្នះក្តីហើយ តែចុងចម្លើយមិនស្ម័គ្រចិត្តបង់លុយឲ្យសោះ…*

*តើអាចយកលុយមកវិញដោយបង្ខំបានឬទេ ?*

*តើត្រូវដាក់ឯកសារអ្វីខ្លះទៅតុលាការ …។ល។*



សូមពន្យល់អំពីការងឿងឆ្ងល់ទាំងអស់នេះ ដូចតទៅ។

# ករណីសិក្សា ( ដូចគ្នា )



នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៦ បានឲ្យ Y ខ្ចី 1 ម៉ឺនដុល្លារអាមេរិក។ ដោយកំណត់កាលបរិច្ឆេទសងនៅថ្ងៃទី 1 ខែកក្កដា។



X



Y

ខ្ញុំមិនបានខ្ចីលុយនោះទេ។

# ករណីសិក្សា ( ដូចគ្នា )




ការទាមទារ : ទាមទារឲ្យសងប្រាក់កម្ចីដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ

# ករណីសិក្សា ( ដូចគ្នា )




សាលក្រមទទួលស្គាល់ការទាមទារ → ចូលជាស្ថាពរ

# ករណីសិក្សា ( ដូចគ្នា )

សាលក្រមបង្គាប់ឲ្យបង់ប្រាក់ 1ម៉ឺនដុល្លារអាមេរិកបានចូលជាស្ថាពរហើយ ក៏ប៉ុន្តែ Y មិនព្រមស្ម័គ្រចិត្តបង់ប្រាក់នោះឡើយ។ តើ X ត្រូវធ្វើយ៉ាងណាដែរ ?




សាលក្រមស្ថាពរនៃប្រាក់ 1ម៉ឺនដុល្លារអាមេរិក

# ការអនុវត្តដោយបង្ខំ

x គិតថា នឹងយកប្រាក់ 1ម៉ឺនដុល្លារអាមេរិកនោះមកវិញដោយបង្ខំ។

x ត្រូវធ្វើនីតិវិធីអ្វីខ្លះ ?

x មិនអានយកប្រាក់មកវិញ ដោយបង្ខំដោយខ្លួនឯងបានឡើយ។

គឺត្រូវប្រើនីតិវិធី ដែលមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី។

នីតិវិធីនោះហៅថា「ការអនុវត្តដោយបង្ខំ」។

# ករណីសិក្សា ( ដូចគ្នា )




សាលក្រមស្ថាពរនៃប្រាក់ 1ម៉ឺនដុល្លារអាមេរិក

# ការអនុវត្តចំពោះអចលនវត្ថុ

អ្វីដែល X កំពុងគិតនោះគឺ លក់អចលនវត្ថុដោយបង្ខំហើយយក សិទ្ធិលើបំណុលរបស់ខ្លួនមកវិញ ពីថ្លៃលក់នោះ។

របៀបអនុវត្តដោយបង្ខំបែបនេះ ហៅថា「ការអនុវត្តដោយបង្ខំ ចំពោះអចលនវត្ថុ」(ចាប់ពីមាត្រា 417)។

តទៅនេះ សូមពន្យល់អំពីនីតិវិធីនៃការអនុវត្តចំពោះអចលនវត្ថុ ។

# ការអនុវត្តចំពោះអចលនវត្ថុ



# [យោង]ការអនុវត្តដោយបង្ខំដែលទាក់ទងនឹងអចលនវត្ថុ

ការអនុវត្តដោយបង្ខំដែល X ទាមទារ គឺជាការលក់អចលនវត្ថុ ដោយមានបំណងយកសិទ្ធិលើបំណុលរបស់ខ្លួនមកវិញពីថ្លៃលក់នោះ។ ការលក់នេះហៅថាការលក់ដោយបង្ខំចំពោះអចលនវត្ថុ (មាត្រា417 កថាខណ្ឌទី2)។ ចំពោះការអនុវត្តដោយបង្ខំដែលទាក់ទងនឹងអចលនវត្ថុមានប្រភេទដូចខាងក្រោមនេះផងដែរ។

- ក្នុងករណីទាមទារឲ្យប្រគល់ : ការអនុវត្តដោយបង្ខំឲ្យប្រគល់អចលនវត្ថុ(មាត្រា 524)
- ក្នុងករណីទាមទារឲ្យចុះបញ្ជី : ការចាត់ទុកថាបានបង្ហាញឆន្ទៈ(មាត្រា 529)

ការអនុវត្តដោយបង្ខំនីមួយៗខុសៗគ្នា ដូច្នេះត្រូវយល់ដោយបែងចែកពីគ្នា ។

# 【យោង】ប្រភេទនៃការអនុវត្តដោយបង្ខំ

1. ការអនុវត្តដោយបង្ខំដែលមានគោលបំណងឲ្យសងជាប្រាក់
   (1) ការអនុវត្តចំពោះចលនវត្ថុ(មាត្រា384～មាត្រា401)
   (2) ការអនុវត្តចំពោះសិទ្ធិលើបំណុលជាអាទិ៍(មាត្រា402～មាត្រា416)
   (3) ការអនុវត្តចំពោះអចលនវត្ថុ (មាត្រា417～មាត្រា453)
   (4) ការអនុវត្តចំពោះនាវា (មាត្រា454～មាត្រា486)

នេះគឺជានីតិវិធីរឹបអូសទ្រព្យសម្បត្តិរបស់កូនបំណុល ដោយលក់ហើយបែងចែកឲ្យទៅម្ចាស់បំណុល ដើម្បីសម្រេចនូវសិទ្ធិលើបំណុលដែលមានគោលបំណងឲ្យសងជាប្រាក់។ ប្រភេទនៃការអនុវត្តដោយបង្ខំគឺខុសគ្នាដោយយោងទៅតាមកម្មវត្ថុនៃគោលបំណង។

2. ការអនុវត្តសិទ្ធិប្រាតិភោគ
   (1) ការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ(មាត្រា500～មាត្រា504)
   (2) ការអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុលជាអាទិ៍(មាត្រា505～មាត្រា508)
   (3) ការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ(មាត្រា509～មាត្រា520)
   (4) ការអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវា(មាត្រា521～មាត្រា523)

នេះគឺជានីតិវិធីអនុវត្តសិទ្ធិប្រាតិភោគ ដើម្បីទទួលនូវការសងពីសិទ្ធិលើបំណុលដែលត្រូវបានធានា។នីតិវិធីនេះដូចគ្នានិងការអនុវត្តសិទ្ធិលើបំណុលដែលមានគោលបំណងឲ្យសងជាប្រាក់ដែរ។

# 【យោង】ប្រភេទនៃការអនុវត្តដោយបង្ខំ

3. ការអនុវត្តដោយបង្ខំដែលពុំមានគោលបំណងឲ្យសងជាប្រាក់

(1) ការអនុវត្តសិទ្ធិទាមទារឲ្យប្រគល់វត្ថុ(មាត្រា524~មាត្រា 526)

(2) ការអនុវត្តជំនួស (មាត្រា 527)

(3) វិធានបង្ខំដោយប្រយោល (មាត្រា528)

(4) ការចាត់ទុកថាបានបង្ហាញឆន្ទៈ (មាត្រា 529)

នេះគឺជានីតិវិធីដែលអនុវត្ត ដើម្បីសម្រេចនូវសិទ្ធិលើបំណុល ក្រៅពីសិទ្ធិលើបំណុលដែលមានគោលបំណងឲ្យសងជាប្រាក់។

# លំហូរនៃនីតិវិធីលក់ដោយបង្ខំចំពោះអចលនវត្ថុ

រឹបអូស

↓

លក់

↓

ចែកចំណែក

**រឹបអូស**

**លក់**

**ចែកចំណែក**

1－1　ដាក់ពាក្យសុំ
1－2　ដីកាសម្រេចចាប់ផ្ដើម
1－3　រឹបអូស
1－4　ទាមទារឲ្យចែកចំណែក

2－1　ស្រាវជ្រាវ
2－2　លក់
2－3　អានុភាព

3－1　រៀបចំ
3－2　ចែកចំណែក

# ករណីសិក្សា (ដូចគ្នា)




សាលក្រមស្ថាពរនៃប្រាក់ 1ម៉ឺនដុល្លារអាមេរិក

# ការដាក់ពាក្យសុំអនុវត្តចំពោះអចលនវត្ថុ

ក្នុងករណីដាក់ពាក្យសុំអនុវត្តចំពោះអចលនវត្ថុ ត្រូវដាក់ឯកសារ ដែលហៅថា「ពាក្យសុំលក់ដោយបង្ខំចំពោះអចលនវត្ថុ」(មាត្រា 349 កថាខណ្ឌទី1)

ជាបឋមសូមពន្យល់ជូន 2 ចំណុច ដូចខាងក្រោម។

1. ទីកន្លែងដែលត្រូវដាក់ពាក្យសុំ
2. ឯកសារដែលចាំបាច់ក្នុងការដាក់ពាក្យសុំ

# ទីកន្លែងដែលត្រូវដាក់ពាក្យ

មុននឹងពន្យល់អំពីទីកន្លែងដែលត្រូវដាក់ពាក្យសុំ សូមបញ្ជាក់អំពី「ស្ថាប័នអនុវត្ត」(មាត្រា336) សិនជាបុរេល័ក្ខខ័ណ្ឌ ។

- ដោយហេតុថា ពាក្យសុំត្រូវដាក់ទៅស្ថាប័នអនុវត្ត។

ស្ថាប័នអនុវត្តគឺជា <u>ស្ថាប័នរដ្ឋ ដែលត្រូវបានផ្តល់សិទ្ធិអំណាចដែលមានបំណងសម្រេចនូវសិទ្ធិ ដោយប្រើអំណាចបង្ខំនៅក្នុងការអនុវត្តដោយបង្ខំ។</u>

# ស្ថាប័នអនុវត្ត

នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី មានស្ថាប័ន ២ ប្រភេទ គឺ「តុលាការអនុវត្ត」និង「អាជ្ញាសាលា」ដែលត្រូវបានកំណត់ថាជាស្ថាប័នអនុវត្ត (មាត្រា336 កថាខណ្ឌទី2)។

- តុលាការអនុវត្ត
  អនុវត្តដោយបង្គំដែលសំខាន់វិនិច្ឆ័យដោយច្បាប់។
  (ឧ.)ការអនុវត្តចំពោះអចលនវត្ថុ

- អាជ្ញាសាលា
  អនុវត្តដោយបង្គំដែលត្រូវធ្វើសកម្មភាពជាក់ស្តែងនៅទីតាំង។

(ឧ)ការអនុវត្តចំពោះចលនវត្ថុ(មាត្រា384កថាខណ្ឌទី1)ការអនុវត្តដោយបង្គំឲ្យប្រគល់អចលនវត្ថុ / ចលនវត្ថុ(មាត្រា524កថាខណ្ឌទី1 មាត្រា525 កថាខណ្ឌទី1)។

# ការបំបែកស្ថាប័នវិនិច្ឆ័យនិងស្ថាប័នអនុវត្តឲ្យដាច់ពីគ្នា

នេះគឺជាការដែលមានតុលាការទទួលបន្ទុកដោះស្រាយបណ្ដឹងហើយ ក្រៅពីនេះមានតុលាការអនុវត្តទៀត ដែលជាស្ថាប័នអនុវត្តទទួលបន្ទុកធ្វើការអនុវត្តដោយបង្ខំ ។

ស្ថាប័នទាំងពីរគឺជាតុលាការដូចគ្នាទេ តើហេតុអ្វីត្រូវបំបែកចេញពីគ្នា?

មូលហេតុគឺមកពីមានការខុសគ្នានៃការ「វិនិច្ឆ័យអំពីអត្ថិភាពឬនត្ថិភាពនៃសិទ្ធិនិងទំហំ」(បណ្ដឹង) និងការ「សម្រេចនូវសិទ្ធិដែលមានអត្ថិភាព」(អនុវត្តដោយបង្ខំ)។

# ការបំបែកស្ថាប័នវិនិច្ឆ័យនិងស្ថាប័នអនុវត្តឲ្យដាច់ពីគ្នា

ក្នុងករណី«វិនិច្ឆ័យអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិនិងទំហំ» តម្រូវឲ្យធ្វើការវិនិច្ឆ័យដោយហ្មត់ចត់ និងដោយនីតិវិធីប្រិតប្រៀង។ ដោយឡែក ចំពោះករណីដែល«សម្រេចនូវសិទ្ធិដែលមានអត្ថិភាព»តម្រូវឲ្យមានកាចាត់ចែងឆាប់រហ័សសាមញ្ញ ។ ដោយសារមានលក្ខណៈខុសគ្នា ដូច្នេះហើយ ទើបគេបំបែកឲ្យដាច់ពីគ្នារវាង<u>ការទទួលបន្ទុកបណ្តឹង និងការទទួលបន្ទុកអនុវត្តដោយបង្ខំ។</u>

# ការបំបែកស្ថាប័នវិនិច្ឆ័យនិងស្ថាប័នអនុវត្តឲ្យដាច់ពីគ្នា

ទន្ទឹមគ្នានិងការបែងចែកការទទួលបន្ទុក ចំពោះនីតិវិធីក៏ត្រូវបាន បំបែកចេញយ៉ាងច្បាស់លាស់ដែរ ។

ស្ថាប័នអនុវត្តមិនវិនិច្ឆ័យអំពីទំហំនិងអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិទេ។ នៅពេលដែលឯកសារដែលចាំបាច់សំរាប់ការអនុវត្តដោយបង្ខំ មានគ្រប់គ្រាន់ហើយ នោះនឹងចាប់ផ្តើមនីតិវិធីអនុវត្តដោយបង្ខំ **តាមលក្ខណៈទម្រង់បែបបទ។**

- ប្រសិនបើស្ថាប័នអនុវត្តត្រូវវិនិច្ឆ័យនូវទំហំព្រមទាំងអត្ថិភាពឬនត្ថិភាពនៃសិទ្ធិម្តងទៀត នោះមិនអាចសម្រេចនូវការអនុវត្តដោយបង្ខំដែលមានភាពឆាប់រហ័សសាមញ្ញបានឡើយ។

វិសាលភាពនៃឯកសារដែលចាំបាច់ ត្រូវបានកំណត់ក្នុងច្បាប់(មាត្រា 350)

# ការបំបែកស្ថាប័នវិនិច្ឆ័យនិងស្ថាប័នអនុវត្តឲ្យដាច់ពីគ្នា

ចំពោះការផ្អាក ឬការលុបចោលនៃនីតិវិធីអនុវត្តដោយបង្ខំ ក៏ដោយ ដូចគ្នាផងដែរ ក្នុងករណីឯកសារដែលចាំបាច់មានគ្រប់គ្រាន់ហើយ នោះការអនុវត្តដោយបង្ខំនឹងត្រូវផ្អាក ឬត្រូវលុបចោល តាមលក្ខណៈទម្រង់បែបបទ (មាត្រា370កថាខណ្ឌទី1 និងកថាខណ្ឌទី2)។

ចំពោះអត្ថិភាព ឬនត្ថិភាពនៃលក្ខខណ្ឌដែលត្រូវលុបចោល ឬផ្អាក តុលាការដែលជាស្ថាប័នវិនិច្ឆ័យ នឹងធ្វើការវិនិច្ឆ័យ។ (មាត្រា367ជាអាទិ៍)។

- ស្ថាប័នអនុវត្តមិនវិនិច្ឆ័យទៅលើលក្ខខណ្ឌនៃការផ្អាក ឬលុបចោលទេ។

# តុលាការអនុវត្ត

សាលាដំបូងនឹងក្លាយជាតុលាការអនុវត្ត(មាត្រា336កថាខណ្ឌទី3)

ការសម្រេចសេចក្តីរបស់តុលាការអនុវត្តត្រូវធ្វើឡើងដោយដីកាសម្រេច(មាត្រា337កថាខណ្ឌទី1)។ ដោយសារជានីតិវិធីសម្រេចសេចក្តីដោយដីកាសម្រេច ដូច្នេះ ពុំចាំបាច់ធ្វើការទាញហេតុផលដោយផ្ទាល់មាត់ឡើយ។(មាត្រា335 មាត្រា114កថាខណ្ឌទី1វាក្យខណ្ឌទី 1)។

- ដើម្បីចាត់ចែងឲ្យបានឆាប់រហ័សសាមញ្ញ។

ក៏ប៉ុន្តែ ក្នុងករណីចាំបាច់ អាចសួរបាន(មាត្រា337កថាខណ្ឌទី2) អាចសួរតាមរយៈឯកសារជាលាយល័ក្ខណ៍អក្សរក៏បានដែរ ដោយសារពុំមែនជានីតិវិធីទាញហេតុផលដោយផ្ទាល់មាត់។

# ទីកន្លែងដែលត្រូវដាក់ពាក្យសុំ

ក្នុងការអនុវត្តចំពោះអចលនវត្ថុ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងនៃអចលនវត្ថុ គឺជាតុលាការអនុវត្ត (មាត្រា418 កថាខណ្ឌទី1)។ ពាក្យសុំអនុវត្តដោយបង្ខំ ត្រូវដាក់ទៅតុលាការអនុវត្តនោះ ។

សូមចាត់ទុកថា ដី L មាននៅក្នុងរាជធានីភ្នំពេញ។ ដូច្នេះ X ត្រូវដាក់ពាក្យសុំទៅសាលាដំបូងរាជធានីភ្នំពេញ ដោយសារតុលាការនោះជាតុលាការអនុវត្ត។

បន្ទាប់មកនេះ សូមបញ្ជាក់មើលឯកសារដែលចំបាច់ក្នុងការដាក់ពាក្យសុំ។

# ឯកសារដែលចាំបាច់ក្នុងការដាក់ពាក្យសុំ

1. លិខិតអនុវត្ត
2. លិខិតបញ្ជាក់ពីការបានបញ្ជូនលិខិតអនុវត្ត
3. រូបមន្តអនុវត្ត
4. ពាក្យសុំលក់ដោយបង្ខំចំពោះអចលនវត្ថុ

# ឯកសារដែលចាំបាច់ក្នុងការដាក់ពាក្យសុំ

1. <u>លិខិតអនុវត្ត</u>
2. លិខិតបញ្ជាក់ពីការបានបញ្ជូនលិខិតអនុវត្ត
3. រូបមន្តអនុវត្ត
4. ពាក្យសុំលក់ដោយបង្ខំចំពោះអចលនវត្ថុ

# លិខិតអនុវត្ត

ដោយសារការបំបែកស្ថាប័នវិនិច្ឆ័យ និងស្ថាប័នអនុវត្តដាច់ពីគ្នា ដូច្នេះ ស្ថាប័នអនុវត្តមិនធ្វើការវិនិច្ឆ័យទេ អំពីអត្ថិភាពនៃសិទ្ធិទាមទារ។ ក្នុងករណី ដែលមានឯកសារបញ្ជាក់ពីអត្ថិភាពនៃសិទ្ធិ ដែលធ្វើឡើងដោយស្ថាប័នវិនិច្ឆ័យត្រូវបានដាក់មក នោះការអនុវត្តដោយបង្ខំនឹងចាប់ផ្តើមដោយលក្ខណៈទម្រង់បែបបទ ។

ឯកសារដែលបញ្ជាក់ជាសាធារណៈនូវអត្ថិភាពនៃសិទ្ធិទាមទាររបស់ម្ចាស់បំណុលនៃការអនុវត្ត ដូចខាងលើនេះហៅថាលិខិតអនុវត្ត ។

ការអនុវត្តដោយបង្ខំ ត្រូវធ្វើឡើងដោយផ្អែកលើលិខិតអនុវត្ត(មាត្រា350 កថាខណ្ឌទី1)។

# លិខិតអនុវត្ត

ប្រភេទនៃលិខិតអនុវត្ត ត្រូវបានកំណត់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី (មាត្រា350 កថាខណ្ឌទី2 ចំណុច ក~ចំណុច ឈ)។

ក្នុងករណីលិខិតអនុវត្តដូចដែលត្រូវបានរាយឡើងនោះ បានដាក់មក ស្ថាប័នអនុវត្តត្រូវតែចាប់ផ្តើមការអនុវត្តដោយបង្ខំ។ ឯកសារក្រៅពីការកំណត់នៃកថាខណ្ឌដូចបានរាយឡើងខាងលើនេះ ដាច់ខាត ពុំអាចក្លាយជាលិខិតអនុវត្តបានទេ។

អានុភាពដែលអាចធ្វើការអនុវត្តដោយបង្ខំបាន ហៅថា「អានុភាពអនុវត្ត」។

# លិខិតអនុវត្ត

លិខិតអនុវត្តមាន ៩ ប្រភេទដូចខាងក្រោមនេះ

1. សាលក្រម ឬសាលដីកាដែលបង្គាប់ឲ្យផ្តល់តាវកាលិកដែលបានចូលជាស្ថាពរ(មាត្រា 350 កថាខណ្ឌទី2 ចំណុច ក មាត្រា195)
2. សាលក្រម ឬសាលដីកាបង្គាប់ឲ្យផ្តល់តាវកាលិកដែលភ្ជាប់ជាមួយនិងការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន(មាត្រា350កថាខណ្ឌទី2 ចំណុច.ខ  មាត្រា 196)
3. ដីកាសម្រេចបង្គាប់ឲ្យផ្តល់តាវកាលិក (មាត្រា 350កថាខណ្ឌទី2 ចំណុច គ)
4. ដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនិងការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន (មាត្រា350 កថាខណ្ឌទី 2 ចំណុច ឃ   មាត្រា328)
5. ការចាត់ចែងរបស់ក្រឡាបញ្ជីដែលកំណត់ជាស្ថាពរនូវចំនួនប្រាក់ប្រដាប់ក្តី(មាត្រា350 កថាខណ្ឌទី2 ចំណុច ង   មាត្រា 66)
6. លិខិតយថាភូតនៃការអនុវត្ត (មាត្រា 350 កថាខណ្ឌទី2 ចំណុច ច)
7. សាលក្រម ឬសាលដីការបស់តុលាការបរទេស ដែលមានសាលក្រមអនុវត្តដែលបានចូលជាស្ថាពរ(មាត្រា350 កថាខណ្ឌទី2 ចំណុច ឆ  មាត្រា352)
8. សេចក្តីសម្រេចមជ្ឈត្តករ ដែលមានដីកាសម្រេចអនុវត្តដែលបានចូលជាស្ថាពរ(មាតា 350 កថាខណ្ឌទី 2 ចំណុច ជ   មាត្រា353 )
9. កំណត់ហេតុស្តីពីការសះជាជាអាទ៏ ដែលជាកំណត់ហេតុមានអានុភាពដូចសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរ (មាត្រា350 កថាខណ្ឌទី2 ចំណុច ឈ  មាត្រា222)

# លិខិតអនុវត្តសំខាន់ៗ

1 សាលក្រម ឬសាលដីកាបង្គាប់ឲ្យផ្ដល់តាវកាលិកដែលបាន ចូលជាស្ថាពរ (មាត្រា350 កថាខណ្ឌទី 2 ចំណុច ក)

នៅពេលសាលក្រម ឬសាលដីកាចូលជាស្ថាពរ (មាត្រា193)អាជ្ញាអស់ជំនុំ (មាត្រា194) នឹងត្រូវកើតឡើង។ ក្នុងករណីនេះ ជាគោលការណ៍គឺអាច អនុវត្តដោយបង្ខំបាន។(មាត្រា195)។

2 សាលក្រម ឬសាលដីកាបង្គាប់ឲ្យផ្ដល់តាវកាលិកដែលភ្ជាប់ ជាមួយនឹងការប្រកាសឲ្យអនុវត្តជាបណ្ដោះអាសន្ន ( កថា ខណ្ឌដដែល ចំណុច ខ )

ក្នុងករណី ការប្រកាសឲ្យអនុវត្តជាបណ្ដោះអាសន្ន ត្រូវបានភ្ជាប់មកជាមួយ (មាត្រា196) ការអនុវត្តដោយបង្ខំអាចអនុវត្តបាន នៅមុនពេលសាលក្រម ឬ សាលដីកាចូលជាស្ថាពរ។

# លិខិតអនុវត្តសំខាន់ៗ

**3**  លិខិតយថាភូតនៃការអនុវត្ត (មាត្រា350 កថាខណ្ឌទី 2 ចំណុច ច)
「 លិខិតយថាភូតនៃការអនុវត្ត 」គឺជាលិខិតដែលបានបំពេញនូវល័ក្ខខ័ណ្ឌ ៣ ដូចតទៅនេះ ។

(1) លិខិតយថាភូតដែលបានបង្កើតឡើងដោយសារការី

(2) ចំពោះសិទ្ធិទាមទារដែលមានបំណងឲ្យសងជាប្រាក់មានកំណត់ ចាំបាច់ត្រូវសរសេរឲ្យបានច្បាស់លាស់នូវចំនួនទឹកប្រាក់នោះ ។

(3) មានសរសេរនូវសេចក្តីថ្លែការណ៍ថា កូនបំណុលនឹងគោរពតាមការអនុវត្តដោយបង្ខំភ្លាមៗ

ដោយសារលិខិតអនុវត្តត្រូវបានបង្កើតឡើងដោយពុំមានការពាក់ព័ន្ធ ពីតុលាការ ហេតុនេះហើយល័ក្ខខ័ណ្ឌត្រូវបានកំណត់យ៉ាងប្រិតប្រៀង ។

# លិខិតអនុវត្តសំខាន់ៗ

4 កំណត់ហេតុស្តីពីការសះជាជាអាទ៍ ដែលជាកំណត់ហេតុមានអានុភាពដូចសាលក្រម ឬសាលដីកាដែលបានចូលជាស្ថាពរ (មាត្រា៣៥០ កថាខណ្ឌទី ២ចំណុច ឈ)

ចំពោះកំណត់ហេតុស្តីពីការសះជា កំណត់ហេតុស្តីពីការទទួលស្គាល់នូវការទាមទារ (មាត្រា222) ជាអាទ៍ មានអានុភាពដូចគ្នានិងសាលក្រមស្ថាពរ ។
ឧទាហរណ៍ : បើកូនបំណុលមិនគោរពតាមខ្លឹមសារ ដែលបានកំណត់នៅក្នុងការផ្សះផ្សាលើបណ្តឹងទេ ម្ចាស់បំណុលអាចអនុវត្តដោយបង្ខំបានភ្លាម ។

# ករណីសិក្សា ( ដូចគ្នា )




សាលក្រមស្ថាពរនៃប្រាក់ 1 ម៉ឺនដុល្លារអាមេរិក

# ឯកសារដែលចាំបាច់ក្នុងការដាក់ពាក្យសុំ

1. លិខិតអនុវត្ត
2. លិខិតបញ្ជាក់ពីការបានបញ្ជូនលិខិតអនុវត្ត
3. រូបមន្តអនុវត្ត
4. ពាក្យសុំលក់ដោយបង្ខំចំពោះអចលនវត្ថុ

# លិខិតបញ្ជាក់ពីការបានបញ្ជូន

លិខិតអនុវត្ត ត្រូវបានបញ្ជូនទៅកូនបំណុលនៃការអនុវត្តជាមុន (មាត្រា360 វាក្យខណ្ឌទី១)។
លិខិតបញ្ជាក់ពីការបានបញ្ជូន គឺបញ្ជាក់ពីការដែលបានបញ្ជូនលិខិតរួចហើយ ។

ចាំបាច់ត្រូវបញ្ជូនលិខិតអនុវត្ត ដើម្បីជូនដំណឹងទុកជាមុន ចំពោះកូនបំណុលនៃការអនុវត្តថា តើខ្លឹមសារអ្វីខ្លះដែលនឹងត្រូវបានអនុវត្តដោយបង្ខំ ។

ដោយឡែក ក្នុងចំណោមលិខិតអនុវត្ត លិខិតសាលក្រមត្រូវបានបញ្ជូនទៅឲ្យភាគីរួចហើយ (មាត្រា190)។ ដូច្នេះពុំចាំបាច់បញ្ជូនម្តងទៀតទេ។

# ករណីសិក្សា ( ដូចគ្នា )

សាលក្រមស្ដាពរនឹងត្រូវបានបញ្ជូនមកមុន
ហើយ ដូច្នេះកាលណាបានទទួលខ្ញុំនឹងដាក់
លិខិតបញ្ជាក់ការបានបញ្ជូននាពេលនោះ ។




សាលក្រមស្ដាពរនៃប្រាក់ 1 ម៉ឺនដុល្លារអាមេរិក

# ឯកសារដែលចាំបាច់ក្នុងការដាក់ពាក្យសុំ

1. លិខិតអនុវត្ត
2. លិខិតបញ្ជាក់ពីការបានបញ្ជូនលិខិតអនុវត្ត
3. រូបមន្តអនុវត្ត
4. ពាក្យសុំលក់ដោយបង្ខំចំពោះអចលនវត្ថុ

# រូបមន្តអនុវត្ត

ការអនុវត្តដោយបង្ខំត្រូវបានធ្វើឡើង ដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្ត (មាត្រា354កថាខណ្ឌទី1 វាក្យខណ្ឌទី១)។

បានសេចក្តីថា បន្ថែមពីលើលិខិតអនុវត្ត (មាត្រា350កថាខណ្ឌទី1)ចំបាច់ត្រូវមានរូបមន្តអនុវត្ត ។

តើហេតុអ្វីមិនត្រឹមតែឲ្យមានលិខិតអនុវត្តប៉ុណ្ណោះទេ ចាំបាច់ត្រូវឲ្យមានដល់ទៅរូបមន្តអនុវត្ត? បើមានត្រឹមតែលិខិតអនុវត្ត គេមិនអាចចាប់ផ្តើមការអនុវត្តដោយបង្ខំឬ?

# រូបមន្តអនុវត្ត

លិខិតអនុវត្ត ទោះបីជាបានបង្កើតឡើងហើយក៏ដោយ  គេមិនដឹងថា តើលិខិតនោះមានអានុភាពនៃការអនុវត្ត ដូចការដែលបានកំណត់ឬពុំមានទេ ។

- ប្រសិនបើ យកសាលក្រមធ្វើជាលិខិតអនុវត្ត សាលក្រមនោះអាចនឹងត្រូវបានលុបចោលដោយការជំនុំជម្រះឧទ្ធរណ៍ ។ ហេតុការណ៍នេះ គេមិនអាចដឹងបានឡើយ បើគ្រាន់តែមើលទៅលើលិខិតសាលក្រម ដែលត្រូវបានដាក់មក។

ស្ថាប័នអនុវត្ត មិនអាចធ្វើការបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃអានុភាពអនុវត្តបានទេ។  ហេតុនេះហើយ ស្ថាប័នដែលបង្កើតលិខិតអនុវត្ត ត្រូវបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃអានុភាពអនុវត្ត។

# រូបមន្តអនុវត្ត

ហេតុនេះហើយ ស្ថាប័នបង្កើតលិខិតអនុវត្តត្រូវធ្វើលិខិតដើម្បីបញ្ជាក់ជាសាធារណៈ នូវអត្ថិភាពនិងទំហំនៃអានុភាពអនុវត្ត ហើយផ្តល់ឲ្យម្ចាស់បំណុលនៃការអនុវត្តដែលលិខិតនោះហៅថា រូបមន្តអនុវត្ត។

ស្ថាប័នអនុវត្តអាចចាប់ផ្តើមនីតិវិធីអនុវត្តដោយបង្ខំបានឆាប់រហ័ស ដោយពិនិត្យមើលលិខិតអនុវត្តនិងរូបមន្តអនុវត្តតាមលក្ខណៈទម្រង់បែបបទ ។

# នីតិវិធីនៃការផ្ដល់រូបមន្តអនុវត្ត

ស្ថាប័នបង្កើតរូបមន្តអនុវត្ត

- ជាគោលការណ៍: រូបមន្តអនុវត្តត្រូវផ្ដល់ដោយក្រឡាបញ្ជីនៃតុលាការដែលមានសំណុំរឿងនោះ (មាត្រា354 កថាខណ្ឌទី2 វាក្យខណ្ឌទី 1) ដោយហេតុថា ដើម្បីធ្វើការវិនិច្ឆ័យថាតើអាច ឬមិនអាចផ្ដល់រូបមន្តអនុវត្ត ចាំបាច់ត្រូវបញ្ជាក់មើលសំណុំរឿងក្ដី ។

- ករណីលើកលែង :ផ្ដល់ដោយសារការីដែលរក្សាទុកនូវច្បាប់ដើម នៃលិខិតបញ្ជាក់ការអនុវត្ត(មាត្រា354 កថាខណ្ឌទី2 វាក្យខណ្ឌទី 1) ដូចគ្នាផងដែរ ត្រូវមានសំណុំរឿងក្ដី ដើម្បីធ្វើការវិនិច្ឆ័យលើល័ក្ខខ័ណ្ឌ ដែលត្រូវផ្ដល់រូបមន្តអនុវត្ត ។

# នីតិវិធីនៃការផ្តល់រូបមន្តអនុវត្ត

ពាក្យសុំផ្តល់រូបមន្តអនុវត្ត(មាត្រា 355 កថាខណ្ឌទី1) ជនដែលចង់បានការផ្តល់រូបមន្តអនុវត្ត ត្រូវដាក់ពាក្យសុំផ្តល់រូបមន្តអនុវត្ត ទៅស្ថាប័នបង្កើតរូបមន្តអនុវត្ត ។

ចំណុចដែលត្រូវសរសេរ (មាត្រា355 កថាខណ្ឌទី 1)

ក : ឈ្មោះ ឬនាមករណ៍និងអាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្តនិងកូនបំណុលនៃការអនុវត្ត ហើយនិងឈ្មោះនិងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

ខ : សញ្ញាណនៃលិខិតអនុវត្ត

គ : ហេតុការណ៍និងមូលហេតុ បើការទាមទារឲ្យផ្តល់រូបមន្តអនុវត្តត្រូវធ្វើឡើងតាមបញ្ញត្តិនៃមាត្រា356 ឬ កថាខណ្ឌទី1 នៃមាត្រា 358នៃក្រមនេះ ។

# នីតិវិធីនៃការផ្តល់រូបមន្តអនុវត្ត

ឯកសារដែលត្រូវដាក់ភ្ជាប់មកជាមួយ (មាត្រា 355 កថាខណ្ឌទី 2)

ក្នុងករណីដែលលិខិតអនុវត្តជាសេចក្តីសម្រេចដែលមិនបង្កើតអានុភាព បើមិនចូលជាស្ថាពរទេ ប្រសិនបើម្ចាស់បំណុលនៃការអនុវត្តដាក់ពាក្យសុំឲ្យផ្តល់រូបមន្តអនុវត្ត ចំពោះលិខិតអនុវត្តនោះ ម្ចាស់បំណុលនៃការអនុវត្តត្រូវភ្ជាប់មកជាមួយពាក្យសុំនូវលិខិតបញ្ជាក់ការចូលជាស្ថាពរនៃសេចក្តីសម្រេចនោះ (មាត្រា355 កថាខណ្ឌទី2 វាក្យខណ្ឌទី 1 )

<សេចក្តីសម្រេចដែលតម្រូវឲ្យចូលជាស្ថាពរ>
សាលក្រម ឬសាលដីកាបង្គាប់ឲ្យផ្តល់តាវកាលិកដែលបានចូលជាស្ថាពរ (មាត្រា350កថាខណ្ឌទី 2 ចំណុច ក )។
ក្នុងចំណោមដីកាសម្រេចបង្គាប់ឲ្យផ្តល់តាវកាលិក ដីកាសម្រេចដែលតម្រូវឲ្យចូលជាស្ថាពរ ( កថាខណ្ឌដដែល ចំណុច គ )។
សាលក្រម ឬសាលដីកាអនុវត្ត និងដីកាសម្រេចអនុវត្តដែលបានចូលជាស្ថាពរ( កថាខណ្ឌដដែល ចំណុច ឆ និង ជ )។

# ពាក្យសុំផ្តល់រូបមន្តអនុវត្ត

ពាក្យសុំផ្តល់រូបមន្តអនុវត្ត

【ភាគី】

ម្ចាស់បំណុលនៃការអនុវត្ត ○○○(អាសយដ្ឋាន)
X(ឈ្មោះ)

កូនបំណុលនៃការអនុវត្ត □□□(អាសយដ្ឋាន)
Y(ឈ្មោះ)

【សញ្ញាណនៃលិខិតអនុវត្ត】

ចំពោះរឿងក្តីរវាងម្ចាស់បំណុលនៃការអនុវត្តនិងកូនបំណុលនៃការអនុវត្ត នៅសាលាដំបូងរាជធានីភ្នំពេញនាឆ្នាំ ២០១៧ (លេខរឿងក្តី លេខសាលក្រម) សាលាដំបូងដដែលខាងលើ បានប្រកាសសាលក្រមនៅថ្ងៃទី □ ខែ ○ ឆ្នាំ ២០១៧ (បានចូលជាស្ថាពរនៅថ្ងៃទី ×ខែ △ នាឆ្នាំដដែល)

# ករណីសិក្សា (ដូចគ្នា)

បានទទួលលិខិតបញ្ជាក់ការចូលជាស្ថាពរហើយ
ឯ ពាក្យសុំផ្តល់រូបមន្តអនុវត្តក៏បានធ្វើរួចហើយដែរ។
ខ្ញុំនឹងយកទៅដាក់ជូនសាលាដំបូងរាជធានីភ្នំពេញ
ដើម្បីទទួលរូបមន្តអនុវត្ត ។




សាលក្រមស្ថាពរនៃប្រាក់1ម៉ឺនដុល្លារអាមេរិក

# នីតិវិធីនៃការផ្តល់រូបមន្តអនុវត្ត

ស្ថាប័នបង្កើតរូបមន្តអនុវត្ត ដែលបានទទួលពាក្យសុំ នឹងធ្វើការបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនិងទំហំនៃអានុភាពអនុវត្តនៃលិខិតអនុវត្ត ។

ប្រសិនបើអានុភាពអនុវត្តដែលកំណត់នៅក្នុងលិខិតអនុវត្តត្រូវបានទទួលស្គាល់ដូចការដែលបានកំណត់នោះ រូបមន្តអនុវត្តនឹងផ្តល់ឲ្យដោយសរសេរភ្ជាប់បន្ថែមនៅផ្នែកក្រោមនៃឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត (មាត្រា357 )។

- នៅជប៉ុន ផ្តល់ឲ្យដោយបន្ថែមលិខិតមួយសន្លឹកដែលមានចំណងជើងថា「រូបមន្តអនុវត្ត」។

ម៉្យាងទៀត ស្ថាប័នបង្កើតរូបមន្តអនុវត្ត ត្រូវសរសេរនៅក្នុងច្បាប់ដើមនៃលិខិតអនុវត្ត នូវការដែលបានផ្តល់រូបមន្តអនុវត្ត(មាត្រា 359 កថាខណ្ឌទី1)។

# នីតិវិធីនៃការផ្តល់រូបមន្តអនុវត្ត

ចំណុចដែលត្រូវសរសេរក្នុងរូបមន្តអនុវត្ត(មាត្រា357 កថាខណ្ឌទី1)

កថាខណ្ឌទី១ ចំណុច ក : បុគ្គលដែលអាចទាមទារឲ្យធ្វើការអនុវត្ត ដោយបង្ខំបាន ដោយលិខិតអនុវត្តនោះ និង ភាគីម្ខាងទៀត។

កថាខណ្ឌទី១ ចំណុច ខ : ហេតុការណ៍ ក្នុងករណីដែលបានផ្តល់រូបមន្ត អនុវត្ត តាមបញ្ញត្តិនៃមាត្រា ៣៥៦ (រូបមន្ត អនុវត្តពិសេស)នៃក្រមនេះ។

កថាខណ្ឌទី១ ចំណុច គ : ទំហំដែលអាចអនុវត្តដោយបង្ខំបាន បើបាន ផ្តល់រូបមន្តអនុវត្តតែមួយផ្នែក នៃសិទ្ធិទាមទារ ដែលត្រូវបានកំណត់នៅក្នុងលិខិតអនុវត្ត ។

កថាខណ្ឌទី២ : ក្រឡាបញ្ជី ឬសារការីត្រូវចុះហត្ថលេខាលើរូប មន្តអនុវត្តដោយសរសេរថ្ងៃ ខែ ឆ្នាំនៃការផ្តល់

# រូបមន្តអនុវត្ត

រូបមន្តអនុវត្ត

ម្ចាស់បំណុលនៃការអនុវត្ត(ដើមចោទ) X(ឈ្មោះ)
កូនបំណុលនៃការអនុវត្ត(ចុងចម្លើយ) Y(ឈ្មោះ)

ម្ចាស់បំណុលនៃការអនុវត្ត អាចអនុវត្តដោយបង្ខំបានចំពោះកូនបំណុលនៃការអនុវត្ត ដោយយោងតាមលិខិតអនុវត្តនេះ ។

ថ្ងៃទី × ខែ △ ឆ្នាំ២០១៧ ក្រឡាបញ្ជី C សាលាដំបូងរាជធានីភ្នំពេញ

※ ដោយសារ ត្រូវចុះនិទ្ទេសនៅក្នុងលិខិតអនុវត្ត ដូច្នេះត្រូវសរសេរផងដែរ នូវស្ថានភាពជា「ដើមចោទ」「ចុងចម្លើយ」។

# ករណីសិក្សា ( ដូចគ្នា )




សាលក្រមស្លាពរនៃប្រាក់1ម៉ឺនដុល្លារអាមេរិក

# ឯកសារដែលចាំបាច់ក្នុងការដាក់ពាក្យសុំ

1. លិខិតអនុវត្ត
2. លិខិតបញ្ជាក់ពីការបានបញ្ជូនលិខិតអនុវត្ត
3. រូបមន្តអនុវត្ត
4. ពាក្យសុំលក់ដោយបង្ខំចំពោះអចលនវត្ថុ

# ពាក្យសុំលក់ដោយបង្ខំចំពោះអចលនវត្ថុ

ចំណុចដែលត្រូវបញ្ជាក់ (មាត្រា349កថាខណ្ឌទី2)

ក : ឈ្មោះ ឬនាមករណ៍និងអាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត ហើយនឹងឈ្មោះនិងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។

ខ : សញ្ញាណនៃលិខិតអនុវត្ត ។

គ : សេចក្តីសុំឲ្យអនុវត្តតាមការបង្ខំដោយផ្ទាល់ ឬការអនុវត្តជំនួស ឬវិធានបង្ខំដោយប្រយោល

ឃ : សញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ និងវិធីអនុវត្តដោយបង្ខំដែលម្ចាស់បំណុលនៃការអនុវត្តសុំ ក្នុងករណីដែលសុំឲ្យអនុវត្តតាមការបង្ខំដោយផ្ទាល់ ។

ង : ខ្លឹមសារនៃសេចក្តីសម្រេចដែលម្ចាស់បំណុលសុំ ក្នុងករណីដែលសុំឲ្យអនុវត្តដោយបង្ខំ តាមការអនុវត្តជំនួស ឬវិធានបង្ខំដោយប្រយោល។

※ ស្តីពីការអនុវត្តតាមការបង្ខំដោយផ្ទាល់ វិធានបង្ខំដោយប្រយោល និងការអនុវត្តដោយបង្ខំតាមការអនុវត្តជំនួស នឹងពន្យល់ជូនក្រោយ ។

# ពាក្យសុំលក់ដោយបង្ខំចំពោះអចលនវត្ថុ

ចាំបាច់ត្រូវភ្ជាប់ជាមួយនឹងលិខិតដូចខាងក្រោម។

1. លិខិតចម្លងយថាភូតនៃលិខិតអនុវត្ត ដែលមានអានុភាពអនុវត្ត (មាត្រា349 កថាខណ្ឌទី2 )
   - គឺជាលិខិតចម្លងយថាភូតនៃលិខិតអនុវត្ត ដែលត្រូវបានផ្តល់រូបមន្តអនុវត្ត។

2. លិខិតបញ្ជាក់ការបានបញ្ជូន
   - ដើម្បីញ្ជាក់ពីការបានបញ្ជូនលិខិតអនុវត្ត(មាត្រា360)។

3. ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុជាអាទិ៍ (មាត្រា 417 កថាខណ្ឌទី 3 ចំណុច ក និង ខ)
   - ដើម្បីបញ្ជាក់ថា អចលនវត្ថុគឺជាកម្មសិទ្ធិរបស់កូនបំណុល។

កន្លែងត្រូវដាក់គឺតុលាការអនុវត្ត។ ចំពោះករណីរបស់ X គឺត្រូវដាក់ទៅសាលាដំបូងរាជធានីភ្នំពេញ។

# [យោង]ប្រភេទនៃវិធីអនុវត្ត

1 អនុវត្តតាមការបង្ខំដោយផ្ទាល់
គឺជាការដែលស្ថាប័នអនុវត្ត សម្រេចនូវការអនុវត្តសិទ្ធិលើបំណុលដោយការប្រើប្រាស់សិទ្ធិអំណាច។

2 អនុវត្តដោយបង្ខំ តាមការអនុវត្តជំនួស
គឺជាការដែលសម្រេចនូវការអនុវត្តសិទ្ធិលើបំណុល ដោយសាមីខ្លួនម្ចាស់បំណុល ឬដោយតតិយជន ដែលត្រូវបានផ្តល់សិទ្ធិអំណាចពីស្ថាប័នអនុវត្ត ហើយប្រមូលសោហ៊ុយដែលបានចំណាយលើការអនុវត្តនោះពីកូនបំណុល។ អាចអនុវត្តជំនួសបាន ចំពោះកាតព្វកិច្ចដែលជាកាតព្វកិច្ចឲ្យធ្វើសកម្មភាពអ្វីមួយ។

3 វិធានបង្ខំដោយប្រយោល
គឺជាការបង្ខំឲ្យកូនបំណុលអនុវត្តកាតព្វកិច្ចដោយសាមីខ្លួន ដោយបង្គាប់ឲ្យកូនបំណុលបង់ប្រាក់ ចំពោះការដែលមិនអនុវត្តកាតព្វកិច្ច។ វិធានបង្ខំដោយប្រយោលអាចអនុវត្តបាន ចំពោះកាតព្វកិច្ចដែលជាកាតព្វកិច្ចឲ្យធ្វើសកម្មភាពអ្វីមួយ កាតព្វកិច្ចដែលធ្វើសកម្មភាពមិនអាចជំនួសបាន និងកាតព្វកិច្ចដែលមិនឲ្យធ្វើសកម្មភាពអ្វីមួយ ។

# ពាក្យសុំលក់ដោយបង្ខំចំពោះអចលនវត្ថុ

ពាក្យសុំលក់ដោយបង្ខំចំពោះអចលនវត្ថុ

ភាគី ដូចការដែលមានបញ្ជាក់នៅក្នុងឯកសារភ្ជាប់ស្តីពីតារាងភាគី។

លិខិតអនុវត្តនិងសិទ្ធិលើបំណុលដែលទាមទារ ដូចការដែលមានបញ្ជាក់នៅក្នុងឯកសារភ្ជាប់ស្តីពីលិខិតអនុវត្តនិងបញ្ជីរាយសិទ្ធិលើបំណុលដែលទាមទារ។

អចលនវត្ថុដែលជាកម្មវត្ថុអនុវត្ត ដូចការដែលមានបញ្ជាក់នៅក្នុងឯកសារភ្ជាប់ស្តីពីបញ្ជីវត្ថុ

※ 「ឯកសារភ្ជាប់」ជាឯកសារដែលប្រើក្នុងការងារជាក់ស្តែងនៅជប៉ុន។

# ពាក្យសុំលក់ដោយបង្ខំចំពោះអចលនវត្ថុ

ពាក្យសុំលក់ដោយបង្ខំចំពោះអចលនវត្ថុ

ម្ចាស់បំណុលនៃការអនុវត្ត មានសិទ្ធិលើបំណុល ដែលត្រូវបានកំណត់ក្នុងឯកសារភ្ជាប់ ស្ដីពីលិខិតអនុវត្តនៃបញ្ជីសិទ្ធិទាមទារ ចំពោះកូនបំណុលនៃការអនុវត្ត ក៏ប៉ុន្តែកូនបំណុលនៃការអនុវត្តពុំព្រមសងទេ។ ហេតុនេះ ទាមទារឲ្យលក់ដោយបង្ខំចំពោះអចលនវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុល ដែលមានកំណត់ក្នុងឯកសារភ្ជាប់ ស្ដីពីបញ្ជីវត្ថុ ។

# ពាក្យសុំលក់ដោយបង្ខំចំពោះអចលនវត្ថុ

**តារាងភាគី**

| | |
|---|---|
| ម្ចាស់បំណុលនៃការអនុវត្ត | ○○○(អាសយដ្ឋាន) |
| | X(ឈ្មោះ) |
| កូនបំណុលនៃការអនុវត្ត | □□□(អាសយដ្ឋាន) |
| | Y (ឈ្មោះ) |

# ពាក្យសុំលក់ដោយបង្ខំចំពោះអចលនវត្ថុ

**លិខិតអនុវត្ត និងបញ្ជីរាយសិទ្ធិលើបំណុលដែលទាមទារ**

ទឹកប្រាក់ខាងក្រោម ដែលត្រូវបានកំណត់នៅក្នុងអនុសារ សាលក្រមដែលមានអានុភាពអនុវត្ត នៃរឿងក្ដីរវាងម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត នៃសាលាដំបូងរាជធានីភ្នំពេញនាឆ្នាំ ២០១៧ (លេខសំណុំរឿង លេខសាលក្រម) ។

កំណត់
១ម៉ឺនដុល្លារអាមេរិក

※ កំណត់អត្តសញ្ញាណនៃលិខិតអនុវត្ត ដោយផ្អែកលើលេខសំណុំរឿង លេខសាលក្រមជាអាទិ៍។

# ពាក្យសុំលក់ដោយបង្ខំចំពោះអចលនវត្ថុ

## បញ្ជីវត្ថុ

ឈ្មោះខេត្ត/ក្រុង

ឈ្មោះស្រុក/ខណ្ឌ

ឈ្មោះឃុំ/សង្កាត់

ឈ្មោះភូមិ

លេខក្បាលដី/លេខប័ណ្ណកម្មសិទ្ធិ

ឈ្មោះកម្មសិទ្ធិករនិងអាសយដ្ឋាន

# សរុបសេចក្ដីអំពីការដាក់ពាក្យសុំ

សរុបសេចក្ដីទៅ ឯកសារចាំបាច់ដែលត្រូវដាក់ដើម្បីសុំអនុវត្ត ចំពោះអចលនវត្ថុ ដោយយកសាលក្រម ឬសាលដីកាស្ថាពរធ្វើជាលិខិតអនុវត្ត មានដូចខាងក្រោម៖

- ពាក្យសុំលក់ដោយបង្ខំចំពោះអចលនវត្ថុ
- លិខិតអនុវត្ត
- លិខិតបញ្ជាក់ការបានបញ្ជូន
- រូបមន្តអនុវត្ត(ចុះនិទ្ទេសក្នុងលិខិតអនុវត្ត)
  - ពាក្យសុំផ្ដល់រូបមន្តអនុវត្ត
  - លិខិតបញ្ជាក់អំពីសាលក្រម ឬសាលដីកាចូលជាស្ថាពរ
- ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់ នៃសៀវភៅចុះបញ្ជីអចលនវត្ថុ
- ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន (ក្នុងករណីប្ដូរពីការរឹបអូសជាបណ្ដោះអាសន្នទៅជាការរឹបអូសពិតប្រាកដ (ពន្យល់ក្រោយ))

**រឹបអូស**

1−1 ដាក់ពាក្យសុំ
<u>1−2 ដីកាសម្រេចចាប់ផ្តើម</u>
1−3 រឹបអូស
1−4 ទាមទារឲ្យចែកចំណែក

**លក់**

2−1 ស្រាវជ្រាវ
2−2 លក់
2−3 អានុភាព

**ចែកចំណែក**

3−1 រៀបចំ
3−2 ចែកចំណែក

# ករណីសិក្សា (ដូចគ្នា)

តើតុលាការដែលបានទទួលពាក្យសុំឲ្យអនុវត្តចំពោះអចលនវត្ថុ ត្រូវអនុវត្តនីតិវិធីអ្វីដែរ។



# ការចាប់ផ្តើមលក់ដោយបង្ខំចំពោះអចលនវត្ថុ

សាលាដំបូងដែលបានទទួលពាក្យសុំអនុវត្តចំពោះអចលនវត្ថុនឹងធ្វើការបញ្ជាក់មើលលិខិតដែលបានដាក់មក។ ប្រសិនបើពាក្យសុំនោះត្រឹមត្រូវតាមច្បាប់ ហើយឯកសារចាំបាច់មានគ្រប់គ្រាន់ ត្រូវតែចាប់ផ្តើមនីតិវិធីនៃការលក់ដោយបង្ខំចំពោះអចលនវត្ថុ។

- ក្នុងករណីបើមានឯកសារគ្រប់គ្រាន់តាមទម្រង់បែបបទហើយបើពុំចាប់ផ្តើមនីតិវិធីទេ នោះពុំត្រូវបានអនុគ្រោះឡើយ។

ជាក់ស្តែង គឺតុលាការត្រូវចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ(មាត្រា419 កថាខណ្ឌទី1)។ ម៉្យាងទៀត ប្រកាសអំពីការរឹបអូសអចលនវត្ថុ ដើម្បីម្ចាស់បំណុលនៃការអនុវត្ត ក្នុងដីកាសម្រេចចាបផ្តើមនោះ។ (កថាខណ្ឌដដែល)។

# ដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំចំពោះអចលនវត្ថុ

ដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំចំពោះអចលនវត្ថុ

| | |
|---|---|
| ភាគី | ដូចការដែលមានបញ្ជាក់នៅក្នុងឯកសារភ្ជាប់ស្ដីពីតារាងភាគី។ |
| លិខិតអនុវត្តនិងសិទ្ធិលើបំណុលដែលទាមទារ | ដូចការដែលមានបញ្ជាក់នៅក្នុងឯកសារភ្ជាប់ស្ដីពីលិខិតអនុវត្តនិងបញ្ជីរាយសិទ្ធិលើបំណុលដែលទាមទារ។ |
| អចលនវត្ថុដែលជាកម្មវត្ថុអនុវត្ត | ដូចការដែលមានបញ្ជាក់នៅក្នុងឯកសារភ្ជាប់ស្ដីពីបញ្ជីវត្ថុ |

※「ឯកសារភ្ជាប់」ជាឯកសារដែលប្រើក្នុងការងារជាក់ស្ដែងនៅជប៉ុន។

# ដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំចំពោះអចលនវត្ថុ

ដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំចំពោះអចលនវត្ថុ

ផ្អែកតាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត តុលាការចាប់ផ្តើមការលក់ដោយបង្ខំ នូវអចលនវត្ថុរបស់កូនបំណុលនៃការអនុវត្ត ដែលមានកំណត់នៅក្នុងឯកសារភ្ជាប់ស្តីពីបញ្ជីវត្ថុ ព្រមទាំងរឹបអូសអចលនវត្ថុនោះ ដើម្បីម្ចាស់បំណុលនៃការអនុវត្ត និង ដើម្បីបំពេញការសងសិទ្ធិលើបំណុលដែលទាមទារ ដែលមានកំណត់នៅក្នុងឯកសារភ្ជាប់ ស្តីពីលិខិតអនុវត្ត និងបញ្ជីរាយសិទ្ធិលើបំណុលដែលទាមទារ ។ ការអនុវត្តនេះធ្វើឡើងដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលមានអានុភាពអនុវត្តលើបញ្ជីរាយសិទ្ធិលើបំណុលដដែលខាងលើ។

ថ្ងៃទី × ខែ △ ឆ្នាំ២០១៧ ចៅក្រម D សាលាដំបូងរាជធានីភ្នំពេញ

# សញ្ញាណនៃលិខិតអនុវត្ត

ការអនុវត្តដោយបង្ខំ គឺជារបបបង្កើតឡើងដើម្បីសម្រេចនូវសិទ្ធិទាមទារឲ្យផ្តល់តាវកាលិករបស់ម្ចាស់បំណុលនៃការអនុវត្តចំពោះកូនបំណុលនៃការអនុវត្ត ។
ស្ថាប័នអនុវត្តនឹងធ្វើការវិនិច្ឆ័យអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិទាមទារឲ្យផ្តល់តាវកាលិក តាមលក្ខណៈទម្រង់បែបបទ ដោយផ្អែកលើលិខិតអនុវត្ត ។

ហេតុដូច្នេះ <u>នៅក្នុងលិខិតអនុវត្ត ត្រូវបង្ហាញឲ្យបានច្បាស់លាស់ថាគឺជាសិទ្ធិទាមទារឲ្យផ្តល់តាវកាលិក និង ទំហំនៃសិទ្ធិទាមទារឲ្យផ្តល់តាវកាលិកនោះ ។</u>

# លិខិតអនុវត្តដែលអាចអនុវត្តបានដោយពុំមានបញ្ហា

**សាលក្រម**
**បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់មួយម៉ឺនដុល្លារអាមេរិក ចំពោះដើមចោទ ។**

ដោយការសរសេរថា「បង់」គឺបានបង្ហាញឲ្យឃើញច្បាស់ថា នេះគឺជាសិទ្ធិទាមទារឲ្យផ្តល់តាវកាលិក។

ចំនួនទឹកប្រាក់「មួយម៉ឺនដុល្លារអាមេរិក」ក៏ត្រូវបានកំណត់បញ្ជាក់ច្បាស់លាស់ផងដែរ ។

ហេតុដូច្នេះ ការអនុវត្តចំពោះអចលនវត្ថុនេះ អាចចាប់ផ្តើមបានដោយពុំមានបញ្ហាឡើយ ។

# លិខិតអនុវត្តដែលមានបញ្ហា(១)

សាលក្រម
បង្គាប់ឲ្យចុងចម្លើយមានកាតព្វកិច្ចបង់ប្រាក់មួយម៉ឺនដុល្លារអាមេរិក ចំពោះដើមចោទ។

ត្រូវបញ្ជាក់ច្បាស់លាស់ថាលិខិតអនុវត្តគឺជា ការបង្គាប់ឲ្យផ្តល់តាវកាលិក ។

ការសរសេរថា「មានកាតព្វកិច្ចបង់ប្រាក់មួយម៉ឺនដុល្លារអាមេរិក」នេះ តើគឺជាការបង្គាប់ឲ្យផ្តល់តាវកាលិក ឬគ្រាន់តែជាការបញ្ជាក់អំពីអត្ថិភាពនៃកាតព្វកិច្ច មិនច្បាស់លាស់សោះ។ ហេតុដូច្នេះ លិខិតអនុវត្តបែបនេះមិនអាចធ្វើការអនុវត្តដោយបង្ខំបានទេ ។

តុលាការអនុវត្តត្រូវលើកចោលពាក្យសុំនោះ។ ចំពោះដីកាសម្រេចលើកចោលពាក្យសុំឲ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ម្ចាស់បំណុលនៃការអនុវត្តអាចប្តឹងជំទាស់បាន (មាត្រា419 កថាខណ្ឌទី3 )។

# លិខិតអនុវត្តដែលមានបញ្ហា(២)

**សាលក្រម**
**បង្គាប់ឲ្យចុងចម្លើយចែកពាក់កណ្តាលនៃទ្រព្យសម្បត្តិចំពោះដើមចោទ។**

នៅក្នុងលិខិតអនុវត្ត ត្រូវកំណត់ឲ្យបានច្បាស់លាស់នូវ ទំហំនិងចំនួនទឹកប្រាក់ជាអាទិ៍នៃកាតព្វកិច្ចដែលត្រូវផ្តល់តាវកាលិក

ការសរសេរថា「 ពាក់កណ្តាលនៃទ្រព្យសម្បត្តិ 」នេះ ជាក់ស្តែងមិនដឹងថា តើត្រូវផ្តល់តាវកាលិកទ្រព្យសម្បត្តិណាទេ ទោះបីជាស្ថាប័នអនុវត្តចង់អនុវត្តក៏ដោយ ក៏មិនអាចអនុវត្តបានដែរ។ ហេតុដូច្នេះ លិខិតអនុវត្តបែបនេះមិនអាចអនុវត្តដោយបង្ខំបានទេ។

តុលាការអនុវត្តត្រូវលើកចោលពាក្យសុំនោះ។ ចំពោះដីកាសម្រេចលើកចោលពាក្យសុំឲ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ម្ចាស់បំណុលនៃការអនុវត្ត អាចប្តឹងជំទាស់បាន (មាត្រា419 កថាខណ្ឌទី3 )។

# សញ្ញាណនៃលិខិតអនុវត្ត

លិខិតអនុវត្ត គឺជាលិខិតដែលបង្កើតឡើងដោយតុលាការ និងសារការី ។

ប្រសិនបើ បង្កើតនូវលិខិតអនុវត្តដែលពុំអាចអនុវត្តដោយបង្ខំបានទេ នោះពុំអាចសម្រេចនូវសិទ្ធិរបស់ភាគីដែលបានទទួលសាលក្រមពីការឈ្នះក្តីឡើយ។

ដើម្បីកុំឲ្យមានករណីបែបនេះកើតឡើង ត្រូវយកចិត្តទុកដាក់នៅពេលបង្កើតលិខិតអនុវត្ត ។

**រឹបអូស**

1－1 ដាក់ពាក្យសុំ
1－2 ដីកាសម្រេចចាប់ផ្តើម
**1－3 រឹបអូស**
1－4 ទាមទារឲ្យចែកចំណែក

↓

**លក់**

2－1 ស្រាវជ្រាវ
2－2 លក់
2－3 អានុភាព

↓

**ចែកចំណែក**

3－1 រៀបចំ
3－2 ចែកចំណែក

# ករណីសិក្សា (ដូចគ្នា)

ពេលណានីតិវិធីលក់ដោយបង្ខំចំពោះអចលនវត្ថុត្រូវបានចាប់ផ្តើម  អចលនវត្ថុនឹងត្រូវបានរឹបអូស។



សាលាដំបូង

រឹបអូស



ដី L




សាលក្រមស្ដាពរនៃប្រាក់ 1ម៉ឺនដុល្លារអាមេរិក

# ការរឹបអូស

ហេតុអ្វីត្រូវរឹបអូស ?

បើមិនរឹបអូសទេ Y អាចលក់ដី L ឲ្យ

ទៅតតិយជនបាន ដើម្បីរួចផុតពីការអនុវត្ត

ដោយបង្ខំ ។

# ករណីសិក្សា (បន្ថែមស្ថានភាព)

លក់ដី L ចោលសិន  ព្រោះ X ដូចជាបានដាក់ពាក្យសុំអនុវត្ត
ដោយបង្ខំហើយ ។



# ការរឹបអូស

X មិនអាចយកសិទ្ធិលើបំណុលរបស់ខ្លួនមកវិញបាន ឡើយ  ដោយសារការធ្វើអនុប្បទានលើដី L របស់Y ។ ដើម្បីបង្ការស្ថានភាពបែបនេះ  ត្រូវធ្វើការរឹបអូស ។

ម្យ៉ាងទៀត ប្រកាសជាសាធារណៈអំពីការរឹបអូសនោះ តាមរយៈការចុះបញ្ជី ។  ការធ្វើនេះគឺដើម្បីឲ្យតតិយជនដែលចង់ទិញដីL  អាចដឹងថាដីL ត្រូវបានរឹបអូស តាមរយៈការបញ្ជាក់មើលការចុះបញ្ជី។

# ការរឹបអូស

នៅពេលដែលដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំចំពោះអចលនវត្ថុ ត្រូវបានអនុវត្ត

1. ធ្វើការចុះបញ្ជីអំពីការរឹបអូស ( មាត្រា420)
2. បញ្ជូនដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ(មាត្រា421កថាខណ្ឌទី2)

អានុភាពនៃការរឹបអូសនឹងត្រូវបានកើតឡើង នៅពេល「 1 」ឬ「 2 」ត្រូវបានអនុវត្តមុន (មាត្រា421កថាខណ្ឌទី2)។

នៅក្នុងការងារជាក់ស្តែងរបស់ជប៉ុន ក្រោយពេលការចុះបញ្ជី (1) អំពីការរឹបអូសបានធ្វើរួចរាល់ហើយ ទើបធ្វើការបញ្ជូន(2)។

- ដោយហេតុថា ប្រសិនបើធ្វើការបញ្ជូនមុន កូនបំណុលនៃការអនុវត្តអាចផ្ទេរឈ្មោះចុះបញ្ជីឲ្យទៅតតិយជនបាន នៅមុនពេលអានុភាពនៃការរឹបអូសបានកើតឡើយ ដើម្បីរួចផុតពីការអនុវត្តដោយបង្ខំ។

# ការរឹបអូស

(ឧទាហរណ៍ 1)
ចុះបញ្ជីអំពីការរឹបអូស : ថ្ងៃទី 20 ខែមករា ឆ្នាំ 2017
បញ្ជូនលិខិត : ថ្ងៃទី 10 ខែមករា ឆ្នាំ 2017
→ អានុភាពនៃការរឹបអូសកើតឡើងនៅថ្ងៃទី 10 ខែមករា ឆ្នាំ 2017(មាត្រា421កថាខណ្ឌទី2 វាក្យខណ្ឌទី1)។

( ឧទាហរណ៍ 2)
ចុះបញ្ជីអំពីការរឹបអូស : ថ្ងៃទី 10 ខែមករា ឆ្នាំ 2017
បញ្ជូនលិខិត : ថ្ងៃទី 20 ខែមករា ឆ្នាំ 2017
→ អានុភាពនៃការរឹបអូសកើតឡើងនៅថ្ងៃទី 10 ខែមករា ឆ្នាំ 2017(មាត្រា421កថាខណ្ឌទី2 វាក្យខណ្ឌទី1 )

※ការងារជាក់ស្តែងនៅជប៉ុនគឺយកលំដាប់នៃ( ឧទាហរណ៍ 2)

# ការចុះបញ្ជីអំពីការរឹបអូស

បើដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំត្រូវបានចេញ ក្រឡាបញ្ជីត្រូវផ្តុកផ្តាក់ឲ្យស្ថាប័នដែលមានសមត្ថកិច្ច ចុះបញ្ជីអំពីការរឹបអូសដែលពាក់ព័ន្ធនឹងដីកាសម្រេចចាប់ផ្តើមនោះជាបន្ទាន់ (មាត្រា420កថាខណ្ឌទី1)។

- ពុំតម្រូវឲ្យម្ចាស់បំណុលនៃការអនុវត្តដាក់ពាក្យសុំដោយឡែកទេ។

តទៅនេះសូមហៅកាត់ ចំពោះប្រការនៃប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនិងក្រមនីតិវិធីរដ្ឋប្បវេណី ថា「ប្រការ」។

ទីផ្តុកផ្តាក់ ៈ រដ្ឋបាលសុរិយោដីរាជធានី／ខេត្ត(ប្រការ 4 និងប្រការ 2 កថាខណ្ឌទី1)

លិខិតត្រូវដាក់ ៈ

- លិខិតផ្តុកផ្តាក់ឲ្យចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ(ប្រការ 5និង7 )
- ឯកសារចម្លងយថាភូតនៃដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ (ប្រការ 6 និង 7 )

# ការចុះបញ្ជីអំពីការរឹបអូស

បើបានធ្វើការចុះបញ្ជីអំពីការរឹបអូស ដោយផ្អែកលើការផ្ទុកផ្ដាក់តាមបញ្ញត្តិនៃកថាខណ្ឌទី១ខាងលើនេះ ស្ថាប័នដែលមានសមត្ថកិច្ចត្រូវផ្ញើឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជីនោះ ទៅក្រឡាបញ្ជី (មាត្រា420កថាខណ្ឌទី2 ប្រការ38)។

បើក្រឡាបញ្ជីពិនិត្យឃើញថា ឯកសារថតចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅគោលបញ្ជីដីធ្លី ឬសៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ ឬសៀវភៅចុះបញ្ជីផលុបភោគ ដែលត្រូវបានផ្ញើមកក្រឡាបញ្ជី ចុះមិនបានត្រឹមត្រូវទៅតាមលិខិតផ្ទុកផ្ដាក់របស់ក្រឡាបញ្ជីដូចជា មានចំណុចខ្វះ ឬចំណុចដែលមិនត្រឹមត្រូវ ឬការសរសេរខុសខ្ទង់(Column) ជាអាទិ៍ ក្រឡាបញ្ជីអាចឲ្យរដ្ឋបាលសុរិយោដីរាជធានី ខេត្ត ធ្វើការកែតម្រូវឲ្យបានត្រឹមត្រូវឡើងវិញបាន។

ក្រោយពីរដ្ឋបាលសុរិយោដីបានធ្វើការកែតម្រូវរួចហើយ បញ្ញត្តិនៃប្រការ ៣៨ ក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរ (ប្រការ 39)។

# ករណីសិក្សា ( ដូចគ្នា )

ពេលទៅបញ្ជាក់មើលសៀវភៅគោលបញ្ជីដីធ្លី ដឹង
ថាការចុះបញ្ជីអំពីការរឹបអូសបានចប់រួចរាល់
ហើយ។ អីចឹង អាចបង្ការការចាត់ចែងដោយ Y
បានហើយ។




សាលក្រមស្ថាពរនៃប្រាក់1ម៉ឺនដុល្លារអាមេរិក

# អានុភាពនៃការរឹបអូស

ការចាត់ចែងដោយកូនបំណុលនៃការអនុវត្តត្រូវបានកម្រិតដោយការកើតឡើងនៃអានុភាពនៃការរឹបអូស ។

ជាក់ស្តែង បើទោះជាកូនបំណុលនៃការអនុវត្តបានលក់អចលនវត្ថុចំពោះតតិយជនក៏ដោយ ទាក់ទងនិងនីតិវិធីនៃការអនុវត្តដោយបង្ខំ អនុប្បទានកម្មនោះ ត្រូវក្លាយជាមោឃៈ។

■ទោះបីជាបានចុះបញ្ជីផ្ទេរកម្មសិទ្ធិ ក្រោយពេលចុះបញ្ជីរឹបអូសក៏ដោយ សិទ្ធិនោះត្រូវរលត់ (មាត្រា431កថាខណ្ឌទី2) ដោយសារលទ្ធផលនៃការលក់(ពន្យល់ក្រោយ)។ ការចុះបញ្ជីផ្ទេរកម្មសិទ្ធិ នោះ ត្រូវបានលុបចោល(មាត្រា448កថាខណ្ឌទី1 ចំណុច ខ)។

# អានុភាពនៃការរឹបអូស

ក៏ប៉ុន្តែ អនុប្បទានកម្មនោះ មានសុពលភាព រវាងកូនបំណុលនៃការអនុវត្តនិងតតិយជន។ ឧទាហរណ៍ ប្រសិនបើអានុភាពនៃការរឹបអូស ត្រូវបានរលត់ ដោយសារការដកពាក្យសុំអនុវត្ត នោះតតិយជនអាចធ្វើលទ្ធកម្មនូវកម្មសិទ្ធិបាន។

សូមមើលឧទាហរណ៍ជាក់ស្តែង ។

# អានុភាពនៃការរឹបអូស

X: ម្ចាស់បំណុលនៃការអនុវត្ត
Y: កូនបំណុលនៃការអនុវត្ត
Z: តតិយជន
W: តតិយជន

① ចុះបញ្ជីរឹបអូស



② Y ចុះបញ្ជីបង្កើត
ហ៊ីប៉ូតែកដើម្បី W

③Y ចុះបញ្ជីផ្ទេរកម្មសិទ្ធិឲ្យទៅ Z

# អានុភាពនៃការរឹបអូស

X: ម្ចាស់បំណុលនៃការអនុវត្ត
Y: កូនបំណុលនៃការអនុវត្ត
Z: តតិយជន
W: តតិយជន

① ចុះបញ្ជីរឹបអូស

④លក់ដោយបង្ខំ



② Y ចុះបញ្ជីបង្កើត ហ៊ីប៉ូតែកដើម្បី W

③Y ចុះបញ្ជីផ្ទេរកម្មសិទ្ធិឲ្យទៅ Z

ការចាត់ចែងនៃ②និង ③ ត្រូវក្លាយជាមោឃៈ ទាក់ទងនិងនីតិវិធីអនុវត្ត ។
ការចុះបញ្ជីនៃ ②និង ③ត្រូវបានលុបចោលដោយសារលទ្ធផលនៃការលក់
(មាត្រា448កថាខណ្ឌទី1 ចំណុច ខ)

# អានុភាពនៃការរឹបអូស

X: ម្ចាស់បំណុលនៃការអនុវត្ត
Y: កូនបំណុលនៃការអនុវត្ត
Z: តតិយជន
W: តតិយជន

① ចុះបញ្ជីរឹបអូស

④ ដកពាក្យសុំ



② Y ចុះបញ្ជីបង្កើត ហ៊ីប៉ូតែកដើម្បី W

③ Y ចុះបញ្ជីផ្ទេរកម្មសិទ្ធិឲ្យទៅ Z

ដោយសារការអនុវត្តចំពោះអចលនវត្ថុត្រូវបានដក ការចាត់ចែងនៃ ②និង③ នៅបន្តមានអត្ថិភាពដែលជាការចាត់ចែងមានសុពលភាព

**រឹបអូស**

1－1 ដាក់ពាក្យសុំ
1－2 ដីកាសម្រេចចាប់ផ្ដើម
1－3 រឹបអូស
<u>1－4</u> **ទាមទារឲ្យចែកចំណែក**

↓

**លក់**

2－1 ស្រាវជ្រាវ
2－2 លក់
2－3 អានុភាព

↓

**ចែកចំណែក**

3－1 រៀបចំ
3－2 ចែកចំណែក

# ករណីសិក្សា ( បន្ថែមស្ថានភាព )



# ការទាមទារឲ្យចែកចំណែក

ការទាមទារឲ្យចែកចំណែក គឺជានីតិវិធីចូលរួមក្នុងនីតិវិធីលក់ដោយបង្ខំដែលកំពុងត្រូវបានចាប់ផ្តើម ដើម្បីទទួលការចែកចំណែក នៃម្ចាស់បំណុលក្រៅពីម្ចាស់បំណុលនៃការអនុវត្ត ។ ម្ចាស់បំណុលដែលបានទាមទារឲ្យចែកចំណែក អាចទទួលការចែកចំណែកបាន រហូតដល់ពេលកំណត់ចុងក្រោយ សម្រាប់ការទាមទារឲ្យចែកចំណែក។(មាត្រា453 ចំណុច ខ )

# ការទាមទារឲ្យចែកចំណែក

ម្ចាស់បំណុលដែលអាចទាមទារឲ្យចែកចំណែកត្រូវបានកម្រិតដូចខាងក្រោម៖

1. ម្ចាស់បំណុលដែលមានឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលអាចអនុវត្តដោយបង្ខំបាន(លើកលែងតែម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគប្រត្យក្ស)។(មាត្រា426កថាខណ្ឌទី1 ចំណុច ក)

2. ម្ចាស់បំណុលដែលបានចុះបញ្ជី អំពីការរឹបអូសបណ្ដោះអាសន្ន នៅក្រោយពេលចុះបញ្ជីអំពីការរឹបអូស ដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ ។ (ចំណុច ខ កថាខណ្ឌដដែល )

3. ម្ចាស់បំណុលដែលបានបញ្ជាក់ដោយឯកសារថា មានឯកសិទ្ធិទូទៅ (ក្រមរដ្ឋប្បវេណី មាត្រា783～មាត្រា787) ។ (ចំណុច គ កថាខណ្ឌដដែល )

# ការទាមទារឲ្យចែកចំណែក

ក្នុងករណីដែលអានុភាពនៃការរឹបអូស បានកើតឡើង តុលាការអនុវត្តត្រូវកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឲ្យចែកចំណែក ។(មាត្រា422កថាខ័ណ្ឌទី1)

- ការទាមទារឲ្យចែកចំណែកដែលធ្វើឡើយ ហួសពេលចុងក្រោយសម្រាប់ការទាមទារ គឺមិនត្រឹមត្រូវតាមច្បាប់ទេ។

ការទាមទារឲ្យចែកចំណែក ត្រូវធ្វើឡើងជាលាយល័ក្ខណ៍អក្សរ ដោយសរសេរនូវមូលហេតុ និងចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល ដោយរួមបញ្ចូលទាំងការប្រាក់ និងសិទ្ធិលើបំណុលបន្ទាប់បន្សំឯទៀត។(មាត្រា426 ក័ថាខណ្ឌទី2)

- ត្រូវភ្ជាប់មកជាមួយផងដែរ នូវឯកសារដែលបញ្ជាក់ច្បាស់អំពីលក្ខណសម្បត្តិនៃការទាមទារឲ្យចែកចំណែក ។

បើមានការទាមទារឲ្យចែកចំណែក តុលាការអនុវត្តត្រូវជូនដំណឹងអំពីការណ៍នោះទៅឲ្យម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត។ (មាត្រា426 កថាខណ្ឌទី3)

# ការទាមទារឲ្យចែកចំណែក

លិខិតទាមទារឲ្យចែកចំណែក

| | |
|---|---|
| ម្ចាស់បំណុលនៃការទាមទារ | ○○○(អាសយដ្ឋាន ) |
| ឲ្យចែកចំណែក | V(ឈ្មោះ) |

ម្ចាស់បំណុលនៃការទាមទារឲ្យចែកចំណែក សុំទាមទារចែកចំណែក អំពីរឿងក្តីលក់ដោយបង្ខំចំពោះអចលនវត្ថុ (លេខសំណុំរឿង)ឆ្នាំ២០១៧ តុលាការរាជធានីភ្នំពេញ។

# លិខិតទាមទារឲ្យចែកចំណែក

លិខិតទាមទារឲ្យចែកចំណែក

**【មូលហេតុ និងចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលដែលទាមទារឲ្យចែកចំណែក】**

ប្រាក់កម្ចីដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី1 ខែមករាឆ្នាំ2015 ។

ប្រាក់ដើម 1 ម៉ឺនដុល្លារអាមេរិក

ការប្រាក់នៃការយឺតយ៉ាវ ការប្រាក់យឺតយ៉ាវ 5%ក្នុងមួយឆ្នាំ ដោយគិតចាប់ពីថ្ងៃទី1 ខែ មករា ឆ្នាំ 2016 រហូតដល់ថ្ងៃសងគ្រប់ចំនួន។

**【លក្ខណៈសម្បត្តិនៃការទាមទារឲ្យចែកចំណែក】**

ម្ចាស់បំណុលនៃការទាមទារឲ្យចែកចំណែក មានអនុសារសាលក្រម ដែលមានអានុភាពអនុវត្ត ដាក់ជូនជាឯកសារឧបសម្ព័ន្ធ ។

**【ឯកសារឧបសម្ព័ន្ធ】**

អនុសារសាលក្រម ដែលមានអានុភាពអនុវត្ត ១ ច្បាប់ ។

# ការប្រកាសជាសាធារណៈ និងការដាស់តឿន

លើសពីនេះ តុលាការអនុវត្ត ត្រូវអនុវត្តនីតិវិធីដូចខាងក្រោម

1. ប្រកាសជាសាធារណៈ អំពីការណ៍ដែលដីកាសម្រេចចាប់ផ្តើមត្រូវបានចេញ និងអំពីពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឲ្យចែកចំណែក។ (មាត្រា422កថាខណ្ឌទី2)

នេះគឺជាការជូនដំណឹងចំពោះម្ចាស់បំណុល ដើម្បីផ្តល់ឱកាសឲ្យមកចូលរួមក្នុងនីតិវិធី។ ម្ចាស់បំណុលដែលគ្មានលិខិតអនុវត្តក៏ដោយ ក៏អាចទាមទារឲ្យចែកចំណែកបានដែរ ដោយធ្វើការចុះបញ្ជីរឹបអូសជាបណ្តោះអាសន្ន នៅមុនពេលកំណត់ចុងក្រោយ សម្រាប់ការទាមទារឲ្យចែកចំណែក។(មាត្រា 426 កថាខណ្ឌទី1 ចំណុច ខ)

# ការប្រកាសជាសាធារណៈ និងការដាស់តឿន

2. តុលាការអនុវត្តត្រូវ ដាស់តឿនឲ្យជនដែលបានកំណត់ខាងក្រោមនេះ រាយការណ៍ទៅតុលាការអនុវត្ត អំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិលើបំណុល និងមូលហេតុនិងចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលនោះ នៅមុនពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឲ្យចែកចំណែក ។(មាត្រា422 កថាខណ្ឌទី2)

ក ម្ចាស់បំណុលដែលបានចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន នៅមុនការចុះបញ្ជីអំពីការរឹបអូស ។
ខ ម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគ ដែលត្រូវបានចុះបញ្ជី នៅមុនការចុះបញ្ជីអំពីការរឹបអូស។
គ ស្ថាប័នដែលមានសមត្ថកិច្ចលើពន្ធដារ ឬអាករសាធារណៈផ្សេងទៀត។

※ តុលាការអនុវត្តត្រូវដាស់តឿនចំពោះជន ដែលបានកំណត់នៅក្នុងចំណុច ខ រាយការណ៍អំពីអត្ថិភាព ឬនត្ថិភាពនៃឆន្ទៈអនុវត្តសិទ្ធិប្រាតិភោគ។ ( មាត្រា422 កថាខណ្ឌទី 3 )

ជនដែលបានកំណត់ខាងលើ ត្រូវរាយការណ៍អំពីចំណុចដែលត្រូវបានដាស់តឿនទៅតុលាការអនុវត្ត នៅមុនពេលកំណត់ចុងក្រោយ សម្រាប់ការទាមទារឲ្យចែកចំណែក(មាត្រា 423 កថាខណ្ឌទី1)។

# ការប្រកាសជាសាធារណៈ និងការដាស់តឿន

ក. ម្ចាស់បំណុលដែលបានចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន

ម្ចាស់បំណុលនេះ មានឋានៈ ទទួលការចែកចំណែកដោយធម្មតា ដែលពុំមានអ្វីគួរឲ្យងឿងឆ្ងល់ឡើយ (មាត្រា453 ចំណុច គ)។ តុលាការអនុវត្តត្រូវក្តាប់នូវចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលជាអាទិ៍របស់ជននោះ។ ហេតុនេះហើយ ត្រូវធ្វើការដាស់តឿន ។

ខ. ម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគ ដែលត្រូវបានចុះបញ្ជីនៅមុនការចុះបញ្ជីអំពីការរឹបអូស។

សិទ្ធិប្រាកិភោគនេះ ទោះបីជាបានលក់អចលនវត្ថុហើយក៏ដោយ ក៏មិនរលត់ដែរ(មាត្រា ៨៣១កថាខណ្ឌទី១)។ ដើម្បីធ្វើការវាយតម្លចំពោះកម្មវត្ថុនៃការអនុវត្ត តុលាការអនុវត្តត្រូវក្តាប់នូវចំនួនទឹកប្រាក់នៃសិទ្ធិប្រាតិភោគដែលត្រូវបានធានា ។ហេតុនេះហើយត្រូវធ្វើការដាស់តឿន ។

# [យោង] ការអនុវត្តសិទ្ធិប្រាតិភោគ

នីតិវិធីនៃការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ (មាត្រា 496~មាត្រា499 មាត្រា509~មាត្រា520) ដូចគ្នានិងការអនុវត្តចំពោះអចលនវត្ថុដែរ គឺធ្វើឡើងដោយវិធីលក់ដោយបង្ខំ។ ខ្លឹមសារនៃនីតិវិធីក៏ស្ទើរតែដូចគ្នាទាំងអស់ដែរ។

សិទ្ធិប្រាតិភោគប្រត្យក្សដែលបានកំណត់នៅក្នុងរដ្ឋប្បវេណី មាន ៥ ប្រភេទ គឺ សិទ្ធិឃាត់ទុក ឯកសិទ្ធិ សិទ្ធិលើការបញ្ចាំ ហ៊ីប៉ូតែក និងសិទ្ធិប្រាតិភោគដោយអនុប្បទាន ( ក្រមរដ្ឋប្បវេណី មាត្រា767 កថាខណ្ឌទី2 )។ ភាគីមិនអាចបង្កើតសិទ្ធិប្រាតិភោគដែលខុសពីនេះដោយការព្រមព្រៀងបានទេ ដែលជាសិទ្ធិពុំមានចែងនៅក្នុងបញ្ញត្តិច្បាប់ ។(មាត្រាដដែលកថាខណ្ឌទី1)

# [យោង] ការអនុវត្តសិទ្ធិប្រាតិភោគ

ក្នុងចំណោមសិទ្ធិដែលបានលើកឡើងទាំងនោះ សិទ្ធិប្រាតិភោគដែលអាចដាក់ពាក្យសុំការលក់ដោយបង្ខំបាន ជាការអនុវត្តសិទ្ធិលើប្រាតិភោគ មានដូចតទៅ ។

- ហ៊ីប៉ូតែក ( ក្រមរដ្ឋប្បវេណី ចាប់ពី មាត្រា 843)
- សិទ្ធិលើការបញ្ចាំអចលនវត្ថុ ( ក្រមរដ្ឋប្បវេណី ចាប់ពី មាត្រា834 )
- ឯកសិទ្ធិ
  - ឯកសិទ្ធិលើអចលនវត្ថុ( ក្រមរដ្ឋប្បវេណី ចាប់ពី មាត្រា 799)
  - ឯកសិទ្ធិទូទៅ( ក្រមរដ្ឋប្បវេណី ចាប់ពី មាត្រា 783)

# [យោខ]ការដាក់ធានា

នៅកម្ពុជា ពីមុនធ្លាប់មានវិធីដាក់ប្រាតិភោគមួយ ដែលហៅថា ការដាក់ធានា (gage) ។

នេះគឺជាការផ្តល់ឥណទាន ដែលផ្តល់ឲ្យដោយប្តូរ និង ប័ណ្ណកម្មសិទ្ធិ ហើយនៅពេលនោះគេមិនបង្កើតហ៊ីប៉ូតែក ឬសិទ្ធិលើការបញ្ចាំជាអាទិ៍ទេ។ វិធីដាក់ធានានេះ បានអនុវត្តយ៉ាងទូលំទូលាយនៅមុនពេលដែលក្រមរដ្ឋប្បវេណីនាបច្ចុប្បន្នកាលនេះបានបង្កើត។

ក៏ប៉ុន្តែ នៅក្នុងក្រមរដ្ឋវេណីបច្ចុប្បន្នកាលនេះ ការដាក់ធានាមិនត្រូវបានទទួលស្គាល់ជាសិទ្ធិប្រាតិភោគទេ ( ក្រមរដ្ឋប្បវេណី មាត្រា767 )។ <u>បច្ចុប្បន្ន ការដាក់ធានាត្រូវបាននិរាករណ៍។</u>

# 【យោខ】ការដាក់ធានា

ហេតុនេះហើយ នៅពេលក្រមរដ្ឋប្បវេណីបានបង្កើត ការដាក់ធានាដែលមានអត្ថិភាពពីមុនមក ត្រូវបានចាត់ទុកជាហ៊ីប៉ូតែក(ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីមាត្រា55 កថាខណ្ឌទី1)

ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីមាត្រា៥៥ កថាខណ្ឌទី១
ការដាក់ធានា (gage) ដោយផ្អែកលើច្បាប់ភូមិបាលឆ្នាំ ២០០១ ត្រូវចាត់ទុកជាហ៊ីប៉ូតែក ដោយផ្អែកលើក្រមរដ្ឋប្បវេណី ក្រោយកាលបរិច្ឆេទនៃការអនុវត្ត។

ប្រសិនបើមានបំណងចង់ធ្វើលទ្ធកម្មលើប្រាតិភោគ មិនអាចប្រើវិធីដាក់ធានាដូចពីមុនបានទេ គប្បីបង្កើតហ៊ីប៉ូតែកនៃក្រមរដ្ឋប្បវេណី។

# ទំនាក់ទំនងនៃការរក្សាការពារនិង ការអនុវត្តដោយបង្ខំ

# ករណីសិក្សា (បន្ថែមស្ថានភាព)



# ករណីសិក្សា (បន្ថែមស្ថានភាព)




② ដាក់ពាក្យបណ្ដឹង

# ការរឹបអូសជាបណ្ដោះអាសន្ននិងការអនុវត្តដោយបង្ខំ

សូមចាត់ទុកថា នៅពេលដែលតុលាការកំពុងចាត់ការរឿងក្ដីរបស់X និង Y ស្រាប់តែ Y បានធ្វើអនុប្បទានដី L ទៅឲ្យតតិយជនបាត់។ ក្នុងករណីនេះ ទោះបីជា X បានឈ្នះក្ដីក៏ដោយ ក៏មិនអានសម្រេចនូវសិទ្ធលើបំណុលឲ្យ X បានដែរ ព្រោះនៅ Y ពុំមានទ្រព្យសម្បត្តិអ្វីដែលអាចអនុវត្តដោយបង្ខំបានទេ ។

របបរឹបអូសជាបណ្ដោះអាសន្ន គឺជារបបរក្សាការពារជាបណ្ដោះអាសន្ន នូវទ្រព្យសម្បត្តិរបស់កូនបំណុល ដើម្បីជៀសវាងស្ថានភាពបែបនេះ ។(មាត្រា545 កថាខណ្ឌទី1)

※ សូមមើលឯកសារយោងនៃសិក្ខាសាលានា ខែកក្កដា ឆ្នាំ2015
https://www.jica.go.jp/project/english/cambodia/014/materials/index.html

# ការរឹបអូសជាបណ្ដោះអាសន្ននិងការអនុវត្តដោយបង្ខំ

- ការរឹបអូសជាបណ្ដោះអាសន្ន

គឺជាការរក្សាការពារទ្រព្យសម្បត្តិរបស់កូនបំណុលជាបណ្ដោះអាសន្ន។ វិធានការនេះធ្វើនៅមុនពេលកំណត់បញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិទាមទារ។

- ការអនុវត្តដោយបង្ខំ (ការអនុវត្តដោយបង្ខំដែលមានគោលបំណងឲ្យសងជាប្រាក់)

គឺជាការសងសិទ្ធិលើបំណុល ដោយការលក់ដោយបង្ខំនូវ ទ្រព្យសម្បត្តិរបស់កូនបំណុល។ វិធានការនេះ ជាគោលការណ៍ ធ្វើនៅក្រោយពេលបានកំណត់បញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិទាមទារ។

# ការរឹបអូសជាបណ្តោះអាសន្ននិងការអនុវត្តដោយបង្ខំ

ការរក្សាការពារនៃបណ្តឹងរដ្ឋប្បវេណី(រឹបអូសជាបណ្តោះអាសន្ន)

បណ្តឹងរដ្ឋប្បវេណី (ការទាមទារឲ្យបង់ប្រាក់)

អនុវត្តដោយបង្ខំ (ការអនុវត្តដោយបង្ខំដែលមានគោលបំណង ឲ្យសងជាប្រាក់ )

# ការរើបអូសជាបណ្ដោះអាសន្ននិងការអនុវត្តដោយបង្ខំ

ការរើបអូសជាបណ្ដោះអាសន្ន និងការអនុវត្តដោយបង្ខំ គឺជានីតិវិធីផ្សេងគ្នា តែទំនាក់ទំនងមាននៅត្រង់ថា ដើម្បីអាចអនុវត្តដោយបង្ខំបាន ត្រូវរើបអូសជាបណ្ដោះអាសន្នទុកជាមុន ។

ដូចដែលបានពន្យល់ខាងលើនេះ ការរើបអូសជាបណ្ដោះអាសន្ន និងការអនុវត្តចំពោះអចលនវត្ថុ គឺជានីតិវិធីដែលធ្វើបន្តបន្ទាប់គ្នា។ ហេតុដូច្នេះហើយ ការប្ដូរពីការរើបអូសជាបណ្ដោះអាសន្នទៅការអនុវត្តដោយបង្ខំនោះ ត្រូវបានទទួលស្គាល់ ។

នៅក្នុងការងារអនុវត្តជាក់ស្ដែងហៅថា「ការប្ដូរទៅការអនុវត្តពិតប្រាកដ」។

# ករណីសិក្សា (បន្ថែមស្ថានភាព)

សាលក្រមទទួលស្គាល់ការទាមទារបាន
ចូលជាស្ថាពរហើយ។ ចាំយកលិខិត
អនុវត្តនេះ ទៅអនុវត្តដោយបង្ខំ។



ដី L

① រឹបអូសជាបណ្ដោះអាសន្ន

X

Y

② សាលក្រមទទួលស្គាល់ការទាមទារចូលជាស្ថាពរ

# ករណីសិក្សា (បន្ថែមស្ថានភាព)




② សាលក្រមស្ថាពរទទួលស្គាល់ការទាមទារ

# ការរឹបអូសជាបណ្ដោះអាសន្ន និងការអនុវត្តដោយបង្ខំ

នៅពេលដែលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុត្រូវបានចេញ ការរក្សាការពារនឹងត្រូវបានអនុវត្ត។ ការអនុវត្តរក្សាការពារគឺជាការអនុវត្ត ដើម្បីសម្រេចនូវគោលដៅនៃដីកាសម្រេចរក្សាកាពារ។

- 「ការអនុវត្តដោយបង្ខំ」 គឺជាការអនុវត្តដើម្បីសម្រេចនូវគោលដៅនៃសាលក្រម ឬសាលដីកាជាអាទ៍។

ជាក់ស្ដែង ត្រូវធ្វើការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន(មាត្រា 567 កថាខណ្ឌទី1)។ នីតិវិធីនៃការចុះបញ្ជីរឹបអូសជាបណ្ដោះអាសន្ន និងអានុភាព មានដូចគ្នានឹងករណីនៃការលក់ដោយបង្ខំដែរ ។(មាត្រាដដែល កថាខណ្ឌទី ៤)។

ប្រសិនបើទាមទារឲ្យប្ដូរទៅការអនុវត្តពិតប្រាកដ ត្រូវបញ្ជាក់ឲ្យច្បាស់លាស់អំពីការណ៍នោះ នៅពេលដាក់ពាក្យសុំអនុវត្តដោយបង្ខំ ។

# ការរឹបអូសជាបណ្តោះអាសន្ន និងការអនុវត្តដោយបង្ខំ

ជាក់ស្តែង នៅក្នុងពាក្យសុំលក់ដោយបង្ខំចំពោះអចលនវត្ថុ ត្រូវសរសេរពីការទាមទារសុំប្តូរពីការរឹបអូសជាបណ្តោះអាសន្នទៅការអនុវត្តពិតប្រាកដ ។

(ឧទាហរណ៍)
រឿងក្តីនេះ គឺជាពាក្យសុំអនុវត្តពិតប្រាកដ ដែលប្តូរពីការរឹបអូសជាបណ្តោះអាសន្ន ដោយដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន (លេខដីកាសម្រេច) សាលាដំបូងក្រុងភ្នំពេញ ចុះថ្ងៃទី ○ ខែ○ ឆ្នាំ២០១៦ ។

ម៉្យាងទៀត ចាំបាច់ត្រូវដាក់ឯកសារចម្លងយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ។ ផ្អែកតាមការណ៍ទាំងអស់នេះ ការរឹបអូសជាបណ្តោះអាសន្ន នឹងប្តូរទៅការអនុវត្តពិតប្រាកដ ។

ផ្អែកតាមការប្តូរទៅការអនុវត្តពិតប្រាកដ  ការចាត់ចែងដែលត្រូវបានធ្វើក្រោយពេលចុះបញ្ជីរឹបអូសជាបណ្តោះអាសន្ន មិនអាចតតាំងនិងម្ចាស់បំណុលនៃការអនុវត្តបានឡើយ។ សិទ្ធិនោះនឹងត្រូវរលត់ដោយការលក់ (មាត្រា431 កថាខណ្ឌទី2 កថាខណ្ឌទី1)។

# ការប្តូរពីការរឹបអូសជាបណ្តោះអាសន្ន ទៅការអនុវត្តពិតប្រាកដ

X: ម្ចាស់បំណុលនៃការអនុវត្ត
Y: កូនបំណុលនៃការអនុវត្ត
Z: តតិយជន
W: តតិយជន

① ចុះបញ្ជីរឹបអូសជាបណ្តោះអាសន្ន

④ ប្តូរទៅការអនុវត្តពិតប្រាកដ



② Y ចុះបញ្ជីបង្កើត ហ៊ីប៉ូតែកដើម្បី W

③ Y ចុះបញ្ជីផ្ទេរកម្មសិទ្ធិឲ្យទៅ Z

# ការប្តូរពីការរឹបអូសជាបណ្តោះអាសន្ន ទៅការអនុវត្តពិតប្រាកដ

X: ម្ចាស់បំណុលនៃការអនុវត្ត
Y: កូនបំណុលនៃការអនុវត្ត
Z: តតិយជន
W: តតិយជន




ដោយការប្តូរពីការអនុវត្តជាបណ្តោះអាសន្នទៅការអនុវត្តពិតប្រាកដ ទាក់ទងនិងនីតិវិធីអនុវត្ត ការចាត់ចែង②និង ③ ត្រូវក្លាយជាមោឃៈ ។

រើបអូស

↓

លក់

↓

ចែកចំណែក

# 「ការលក់」គឺ

･ស្រាវជ្រាវអចលនវត្ថុដែលបានរឹបអូស ហើយកំណត់តម្លៃលក់អប្បបរមាដោយផ្អែកលើស្ថានភាពនិងទំនាក់ទំនងសិទ្ធិនៃអចលនវត្ថុនោះ។

･ផ្សព្វផ្សាយជាសាធារណៈនូវពត៌មាននៃអចលនវត្ថុដែលបានរឹបអូស កំណត់អ្នកទិញដោយវិធីលក់ឡាយឡុងដោយស្រោមសំបុត្រជាអាទិ៍ ហើយឲ្យអ្នកទិញបង់ថ្លៃលក់ ។

･ក្រោយពេលថ្លៃលក់ត្រូវបានបង់ហើយ កម្មសិទ្ធិនៃអចលនវត្ថុនឹងផ្ទេរពីកូនបំណុលនៃការអនុវត្តទៅអ្នកទិញ។

| | |
|---|---|
| **រឹបអូស** | 1－1 ដាក់ពាក្យសុំ<br>1－2 ដីកាសម្រេចចាប់ផ្តើម<br>1－3 រឹបអូស<br>1－4 ទាមទារឲ្យចែកចំណែក |
| ↓ | |
| **លក់** | **2－1 ស្រាវជ្រាវ**<br>2－2 លក់<br>2－3 អានុភាព |
| ↓ | |
| **ចែកចំណែក** | 3－1 រៀបចំ<br>3－2 ចែកចំណែក |

# 2－1ការស្រាវជ្រាវ

ក្នុងករណីលក់អចលនវត្ថុដែលបានរឹបអូស
តើខាងអ្នកទិញមានការចាប់អារម្មណ៍យកចិត្ត
ទុកដាក់ទៅលើចំណុចអ្វីខ្លះ ?

# 2－1ការស្រាវជ្រាវ

ក្នុងនាមជាអ្នកទិញនៃកិច្ចសន្យាលក់ទិញ អ្វីដែលចាប់អារម្មណ៍យកចិត្តទុកដាក់នោះ គឺប្រាកដជាទៅលើ「កម្មវត្ថុនៃការអនុវត្ត」និង「ថ្លៃលក់」ជាមិនខាន។

「ថ្លៃលក់」គឺកំណត់ដោយផ្អែកលើតម្លៃនៃ「 កម្មវត្ថុនៃការអនុវត្ត 」។

បានសេចក្តីថា តុលាការដែលនឹងក្លាយជាអ្នកលក់ត្រូវធ្វើការស្រាវជ្រាវអំពី កម្មវត្ថុនៃការអនុវត្តនិង អំពីតម្លៃនោះ។

# 2－1ការស្រាវជ្រាវ

តើតម្លៃនៃអចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្ត កំណត់ដោយផ្អែកលើកត្តាអ្វីខ្លះ?

ទំហំផ្ទៃដី ទីតាំង ជាដីទំនេរឬអាគារ? តើមាននរណាកំពុងកាន់កាប់ឬទេ ? តើមានភ្ជាប់និងសិទ្ធិប្រាតិភោគឬទេ ?។ល។ គឺជាការណ៍ដែលត្រូវបានគិតទៅដល់ ។

ដូច្នេះត្រូវស្រាវជ្រាវអំពីកត្តាទាំងអស់នេះ ហើយធ្វើការវាយតម្លៃដោយផ្អែកលើលទ្ធផលនោះ។

# 2－1ការស្រាវជ្រាវ

ដើម្បីធ្វើការស្រាវជ្រាវនិងវាយតម្លៃដូចដែលបានពន្យល់ តុលាការអនុវត្តត្រូវជ្រើសតាំងអ្នកវាយតម្លៃ និងបង្គាប់ឲ្យវាយតម្លៃអចលនវត្ថុនោះ។ (មាត្រា430កថាខណ្ឌទី1)

អ្នកវាយតម្លៃដែលត្រូវបានជ្រើសតាំង ត្រូវដាក់ជូនតុលាការអនុវត្តជាលាយល័ក្ខណ៍អក្សរ នូវលទ្ធផលនៃការស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុ និងការវាយតម្លៃអចលនវត្ថុនោះ។(មាត្រា430 កថាខណ្ឌទី5)

# 2－1ការស្រាវជ្រាវ

លេខសំណុំរឿង●●

**លិខិតបង្គាប់ឲ្យធ្វើការវាយតម្លៃ**

អ្នកវាយតម្លៃ UCHIYAMA Jun

ជ្រើសតាំងជនដែលបានកំណត់ខាងលើនេះជាអ្នកវាយតម្លៃ។
បង្គាប់ឲ្យអ្នកវាយតម្លៃធ្វើការវាយតម្លៃចំពោះអចលនវត្ថុ ដែលមានកំណត់នៅក្នុងឯកសារភ្ជាប់ស្តីពីបញ្ជីវត្ថុ។
កំណត់ថ្ងៃទី20 ខែឧសភា ឆ្នាំ2017 ជាកាលកំណត់ត្រូវប្រគល់លិខិតវាយតម្លៃ។

ថ្ងៃទី 21 ខែកុម្ភៈ ឆ្នាំ 2017
សាលាដំបូងរាជធានីភ្នំពេញ ចៅក្រម YUKAWA Ryo

# 2－1ការស្រាវជ្រាវ

## ឯកសារភ្ជាប់ស្តីពីបញ្ជីវត្ថុ

- ឈ្មោះខេត្ត/ក្រុង
- ឈ្មោះស្រុក/ខណ្ឌ
- ឈ្មោះឃុំ/សង្កាត់
- ឈ្មោះភូមិ
- លេខក្បាលដី/លេខប័ណ្ណកម្មសិទ្ធិ
- ឈ្មោះកម្មសិទ្ធិករនិងអាសយដ្ឋាន

# 2－1ការស្រាវជ្រាវ

<សិទ្ធិអំណាចរបស់អ្នកវាយតម្លៃ>

・ដើម្បីសុំជំនួយពីអាជ្ញាសាលា អ្នកវាយតម្លៃត្រូវទទួលការអនុញ្ញាតពីតុលាការអនុវត្ត ។(មាត្រា430 កថាខណ្ឌទី2)

・នៅពេលស្រាវជ្រាវដើម្បីវាយតម្លៃ អ្នកវាយតម្លៃអាចចូលទៅកាន់អចលនវត្ថុ ឬអាចសួរសំណួរ ឬទាមទារឲ្យបង្ហាញឯកសារ ចំពោះកូនបំណុលនៃការអនុវត្ត ឬតតិយជនដែលកាន់កាប់អចលនវត្ថុនោះបាន។(មាត្រា430កថាខណ្ឌទី3)

# 2－1ការស្រាវជ្រាវ

ស្តីពីទំនាក់ទំនងសិទ្ធិនៃអចលនវត្ថុដែលត្រូវបានរឹបអូស ក្នុងនាមជាអ្នកទិញ ប្រាកដជាមានការចាប់អារម្មណ៍និងយកចិត្តទុកដាក់ចំពោះសិទ្ធិជាអាទិ៍ដែលនៅបន្តមានអត្ថិភាពក្រោយពេលលក់ជាមិនខាន ។

ឧទាហរណ៍ ៖ ប្រសិនបើ អចលនវត្ថុដែលបានទិញនោះ ជាអចលនវត្ថុដែលត្រូវបានបន្សល់ទុកនូវហ៊ីប៉ូតែក ទោះបីជាបានទិញហើយក៏ដោយ ជាចុងបញ្ចប់អ្នកទិញអាចនឹងបាត់បង់កម្មសិទ្ធិនោះ  ដោយសារក្រោយមកហ៊ីប៉ូតែកត្រូវបានអនុវត្ត។

# 2－1ការស្រាវជ្រាវ

ហេតុនេះហើយ នៅពេលធ្វើការវាយតម្លៃ ត្រូវវិនិច្ឆ័យអំពីសិទ្ធិដែលនៅបន្តមានអត្ថិភាពក្រោយការលក់ឲ្យអ្នកទិញ និងសិទ្ធិដែលត្រូវរលត់ដោយការលក់ ហើយត្រូវកំណត់តម្លៃអចលនវត្ថុដោយផ្អែកលើលទ្ធផលនៃការវិនិច្ឆ័យនោះ។

ស្តីអំពីសិទ្ធិនៅលើអចលនវត្ថុដែលត្រូវបានរឹបអូស តើសិទ្ធិនោះនឹងបន្តមានអត្ថិភាព ឬត្រូវរលត់ក្រោយកាលក់ នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី នោះនឹងក្លាយជាមូលដ្ឋានសំរាប់ធ្វើការវិនិច្ឆ័យថាតើអាចតតាំងនិងការរឹបអូសឬក៏មិនអាច ?

# 2－1ការស្រាវជ្រាវ

សិទ្ធិដែលត្រូវបានចុះបញ្ជីនៅ មុនពេលអានុភាពនៃការរឹប អូសកើតឡើង→ នៅបន្តមានអត្ថិភាពក្រោយការលក់។ (មាត្រា431 កថាខណ្ឌទី1)

សិទ្ធិដែលត្រូវបានចុះបញ្ជីនៅ ក្រោយពេលអានុភាពនៃការ រឹបអូសកើតឡើង → ត្រូវរលត់ក្រោយការលក់។ (មាត្រា431កថាខណ្ឌទី2)

# 2－1ការស្រាវជ្រាវ

【ឧទាហរណ៍ជាក់ស្តែង】

ប្រសិនបើសិទ្ធិនោះត្រូវបានចុះបញ្ជីតាមលំដាប់ដូចខាងក្រោម···

1 ចុះបញ្ជីបង្កើតហ៊ីប៉ូតែកទី 1 (A→Y)

2 ចុះបញ្ជីបង្កើតហ៊ីប៉ូតែកទី 2 (B→Y)

*3 ចុះបញ្ជីរឹបអូស (X→Y)*

4 ចុះបញ្ជីបង្កើតហ៊ីប៉ូតែកទី 3 (C→Y)

# 2－1ការស្រាវជ្រាវ

សិទ្ធិដែលនៅបន្តមានអត្ថិភាពក្រោយការលក់

គឺហ៊ីប៉ូតែកទី1និង ទី 2 （ទី 3 ត្រូវរលត់）។

1 ចុះបញ្ជីបង្កើតហ៊ីប៉ូតែកទី 1 (A→Y)

2 ចុះបញ្ជីបង្កើតហ៊ីប៉ូតែកទី 2 (B→Y)

***3 ចុះបញ្ជីរឹបអូស(X→Y)***

~~4 ចុះបញ្ជីបង្កើតហ៊ីប៉ូតែកទី 3 (C→Y)~~

# 2－1ការស្រាវជ្រាវ

【គំនិតដែលគិត】

| | | |
|---|---|---|
| តម្លៃនៃអចលនវត្ថុ | 100 | |
| ហ៊ីប៉ូតែកទី 1(A) | 50 | ←នៅបន្តមានអត្ថិភាពក្រោយការលក់ |
| ហ៊ីប៉ូតែកទី 2(B) | 30 | |
| ហ៊ីប៉ូតែកទី 3(C) | 10 | ←ត្រូវរលត់ក្រោយការលក់ |

តើអ្នកទិញត្រូវទិញក្នុងតម្លៃប៉ុន្មាន ?

# 2－1ការស្រាវជ្រាវ

【គំនិតដែលគិត】

តម្លៃនៃអចលនវត្ថុ　100

ហ៊ីប៉ូតែកទី 1(A)　50
ហ៊ីប៉ូតែកទី 2(B)　30

←អ្នកទិញត្រូវទទួលបន្ទុក

~~ហ៊ីប៉ូតែកទី 3(C)　10~~

អ្នកទិញធ្វើលទ្ធកម្មលើអចលនវត្ថុដោយបង់
「100－(50＋30)＝20」
(ហ៊ីប៉ូតែកនៃ A និង B នៅបន្តមានអត្ថិភាព)

# ២–1ការស្រាវជ្រាវ

ដោយសារទំនាក់ទំនងសិទ្ធិអាចនឹងមានការផ្លាស់ប្តូរ ដូច្នេះ ហើយ ទើបអ្នកវាយតម្លៃត្រូវធ្វើការវាយតម្លៃដោយផ្អែកលើ ទំនាក់ទំនងសិទ្ធិដែលនៅបន្តមានអត្ថិភាពក្រោយការលក់។

ហើយ យោងលើការវាយតម្លៃរបស់អ្នកវាយតម្លៃដែលបានធ្វើ ឡើងដោយផ្អែកតាមកត្តាទាំងអស់នេះ តុលាការត្រូវកំណត់ តម្លៃលក់អប្បបរមានៃអចលនវត្ថុដែលរឹបអូសនោះ។ (មាត្រា432 កថាខណ្ឌទី1)

# 2－1ការស្រាវជ្រាវ

តម្លៃអប្បបរមា គឺជាការដែលមិនអាចលក់ដោយតម្លៃតិចជាងនេះ។

នៅពេលត្រូវអនុវត្តការលក់ ក្រឡាបញ្ជីត្រូវផ្សាយជាសាធារណៈនូវសញ្ញាណនៃអចលនវត្ថុដែលត្រូវលក់ តម្លៃលក់អប្បបរមាព្រមទាំងកាលបរិច្ឆេទ និង ទីកន្លែងលក់ ។(មាត្រា436 កថាខណ្ឌទី4)

# 2－1ការស្រាវជ្រាវ

ដោយឡែក ប្រសិនបើតម្លៃលក់អប្បបរមាដែលតុលាការបានកំណត់ នឹងពុំសេសសល់ប្រាក់សំរាប់ចែកចំណែកចំពោះម្ចាស់បំណុលទេ ការលក់នោះពុំមានផលប្រយោជន៍សំរាប់ម្ចាស់បំណុលឡើយ ដូច្នេះ តុលាការអនុវត្តត្រូវជូនដំណឹងអំពីការណ៍នោះទៅឲ្យម្ចាស់បំណុលនៃការអនុវត្ត ជាគោលការណ៍ត្រូវលុបចោលនូវនីតិវិធីនៃការលក់ដោយបង្ខំនោះ។(មាត្រា435 កថាខណ្ឌទី2 វាក្យខណ្ឌទី១)

ករណីលើកលែង ៖ ប្រសិនបើម្ចាស់បំណុលនៃការអនុវត្ត ធ្វើសំណើថាខ្លួននឹងទិញអចលនវត្ថុក្នុងតម្លៃស្នើសុំ ដែលលើសពីតម្លៃសោហ៊ុយសម្រាប់នីតិវិធី និងដាក់ប្រាក់ធានាដែលស្មើនឹងតម្លៃស្នើសុំ ។ (មាត្រា435 កថាខណ្ឌទី2 ចំណុច ក និង ខ)

# 2－1ការស្រាវជ្រាវ

【 ឧទាហរណ៍ជាក់ស្តែង 】

| | |
|---|---|
| តម្លៃនៃអចលនវត្ថុ | 91 |
| ហ៊ីប៉ូតែកទី 1 (A) | 60 |
| ហ៊ីប៉ូតែកទី 2 (B) | 30 |
| សោហ៊ុយសំរាប់នីតិវិធី | 2 |

← នៅបន្តមានអត្ថិភាព ក្រោយការលក់

ដោយសារតម្លៃជាក់ស្តែងនៃអចលនវត្ថុ「91－(60＋30)＝1」តិចជាងសោហ៊ុយសំរាប់នីតិវិធី「2」 ដូច្នេះ ជាគោលការណ៍នីតិវិធីនៃការលក់ត្រូវលុបចោល។

# 2－1ការស្រាវជ្រាវ

ដើម្បីផ្សព្វផ្សាយប្រមូលអ្នកមានបំណងចង់ទិញ ចាំបាច់ត្រូវបង្ហាញឲ្យបានច្បាស់លាស់អំពីពត៌មានស្តីពី「កម្មវត្ថុនៃការអនុវត្ត」និង「ថ្លៃលក់」។

ត្រង់ហ្នឹងហើយ ដែលតុលាការអនុវត្តត្រូវធ្វើឯកសារលំអិតអំពីវត្ថុ ហើយត្រូវទុកឯកសារចម្លងនៃឯកសារលំអិតអំពីវត្ថុនោះនៅតុលាការអនុវត្ត ជាមួយនឹងឯកសារចម្លងនៃរបាយការណ៍វាយតម្លៃ ដើម្បីផ្តល់ឲ្យសាធារណជនមើល។ (មាត្រា434 កថាខណ្ឌទី1)

# 2－1ការស្រាវជ្រាវ

< ចំណុចដែលត្រូវសរសេរក្នុងឯកសារលំអិតអំពីវត្ថុ (មាត្រា434 កថាខ័ណ្ឌទី1ចំណុច ក និងចំណុច ខ) >

1 សញ្ញាណនៃអចលនវត្ថុ

2 សិទ្ធិដែលនឹងបន្តមានអត្ថិភាពក្រោយការលក់ជាអាទ៍
(មាត្រា431 កថាខណ្ឌទី1ជាអាទ៍)

# 2－1ការស្រាវជ្រាវ

លេខសំណុំរឿង●●

## ឯកសារលំអិតអំពីវត្ថុ

1 សញ្ញាណនៃអចលនវត្ថុ

ឈ្មោះខេត្ត/ក្រុង ឈ្មោះ ស្រុក/ខណ្ឌ ឈ្មោះឃុំ/សង្កាត់ ឈ្មោះភូមិ

លេខក្បាលដី/លេខប័ណ្ណកម្មសិទ្ធិ ឈ្មោះកម្មសិទ្ធិករ អាសយដ្ឋាន

2 សិទ្ធិលើអចលនវត្ថុដែលនឹងបន្តមានអត្ថិភាពក្រោយការលក់ជាអាទ៍

គ្មាន

ថ្ងៃទី 21 ខែកុម្ភៈ ឆ្នាំ 2017
សាលាដំបូងរាជធានីភ្នំពេញ ចៅក្រម YUKAWA Ryo

# 2－1ការស្រាវជ្រាវ

1　សញ្ញាណនៃអចលនវត្ថុ

- ត្រូវសរសេរស្របតាមចំណុចដែលមានសរសេរនៅក្នុង「សញ្ញាណនៃអចលនវត្ថុ」នៃការចុះបញ្ជី។

- ឬសរសេរតាមវិធីមួយទៀតថា「ដូចការដែលមានបញ្ជាក់នៅក្នុងឯកសារភ្ជាប់ស្ដីពីបញ្ជីវត្ថុ」។ (ដូចគ្នានិងការអនុវត្តជាក់ស្ដែងនៅជប៉ុន)

# 2－1ការស្រាវជ្រាវ

2 សិទ្ធិដែលនៅបន្តមានអត្ថិភាពក្រោយការលក់( ឧទាហរណ៍ជាក់ស្តែង )

ហ៊ីប៉ូតែក

| | |
|---|---|
| មូលហេតុនៃការបង្កើត | កម្ចីបរិភោគថ្ងៃទី 21 ខែកុម្ភៈ ឆ្នាំ2010 |
| ម្ចាស់បំណុលហ៊ីប៉ូតែក | TSUJI Yasuhiko |
| កូនបំណុល | HIGASHIO Kazuyuki |
| ចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល | 1ម៉ឺនដុល្លារអាមេរិក |
| ការប្រាក់ | 7% ក្នុងមួយឆ្នាំ |
| ការប្រាក់យឺតយ៉ាវ | 10% ក្នុងមួយឆ្នាំ |
| កិច្ចសន្យាពិសេស | គ្មាន |

# 2－1ការស្រាវជ្រាវ

【ចំណុចដែលត្រូវប្រយ័ត្ន】
ទំនាក់ទំនងគតិយុត្តលើច្បាប់សារធាតុនៅក្នុងឯកសារលំអិតអំពីវត្ថុ ពុំមែនជាការណ៍ដែលត្រូវបានកំណត់ជាស្ថាពរដោយការវិនិច្ឆ័យរបស់តុលាការទេ។

ហេតុដូច្នេះ ប្រសិនបើចេញសាលក្រម ឬសាលដីកាដែលមានខ្លឹមសារខុសពីការសរសេរនៅក្នុងឯកសារលំអិតអំពីវត្ថុ ខ្លឹមសារនៃសាក្រម ឬសាលដីកានឹងត្រូវបានយកជាអាទិភាព ដែលជាលទ្ធផលធ្វើឲ្យខូចផលប្រយោជន៍ចំពោះអ្នកទិញក៏មានដែរ។

**រឹបអូស**

1－1 ដាក់ពាក្យសុំ
1－2 ដីកាសម្រេចចាប់ផ្ដើម
1－3 រឹបអូស
1－4 ទាមទារឲ្យចែកចំណែក

**លក់**

2－1 ស្រាវជ្រាវ
2－2 លក់
2－3 អានុភាព

**ចែកចំណែក**

3－1 រៀបចំ
3－2 ចែកចំណែក

# 2－2 ការលក់

【ពន្យល់ជាសង្ខេបអំពីចំណុចសំខាន់នៃនីតិវិធី】

①កំណត់វិធីលក់ បើកកាលបរិច្ឆេទលក់ ហើយប្រគល់ឲ្យអាជ្ញាសាលាអនុវត្តការលក់។

↓

②កំណត់អ្នកស្នើទិញក្នុងតម្លៃជាអតិបរមា ហើយបើកកាលបរិច្ឆេទដើម្បីចេញដីកាសម្រេចអនុញ្ញាតឲ្យលក់។

↓

③នៅពេលដែលដីកាសម្រេចអនុញ្ញាតឲ្យលក់ចូលជាស្ថាពរ ត្រូវកំណត់នូវពេលកំណត់ដែលត្រូវបង់ថ្លៃលក់ ហើយឲ្យអ្នកទិញបង់ថ្លៃលក់។

# 2－2 ការលក់

ការលក់អចលនវត្ថុ ត្រូវអនុវត្តតាមវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់ ។(មាត្រា 436 កថាខណ្ឌទី1 )

ប្រសិនបើលក់តាមវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់ តុលាការអនុវត្តត្រូវកំណត់កាលបរិច្ឆេទ និងទីកន្លែងលក់ ហើយត្រូវឲ្យអាជ្ញាសាលាអនុវត្តការលក់នោះ ។ ( មាត្រា 436 កថាខណ្ឌទី 3)

※ កូនបំណុលនៃការអនុវត្តពុំអាចធ្វើសំណើទិញបានឡើយ។ ( មាត្រា 438)

# 2－2 ការលក់

ការលក់ឡាយឡុងដោយស្រោមសំបុត្រ គឺជាវិធីលក់ដែលអ្នកមានបំណងចង់ទិញ ដាក់សំណើទិញ(ជាលាយល័ក្ខណ៍អក្សរ)ដោយសរសេរតម្លៃដែលចង់ទិញទៅក្នុងពាក្យសុំទិញការលក់ឡាយឡុងបន្ទាប់មកអនុវត្តការបើកស្រោមសំបុត្រ ហើយកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ។

ខុសគ្នានិង「ការលក់ឡាយឡុងដោយផ្ទាល់មាត់」ដែលតម្រូវឲ្យមានបច្ចេកទេស ឬបទពិសោធន៍ក្នុងការតថ្លៃ វិធីលក់ខាងលើនេះត្រូវបានយល់ឃើញថា ជាគោលការណ៍នៃវិធីលក់ ដោយហេតុថាអាចធ្វើឲ្យសាធារណជនទូទៅមកចូលរួមយ៉ាងទូលំទូលាយ។

# 2－2 ការលក់

នៅជប៉ុន ជាទូទៅវិធីលក់ឡាយឡុងដោយស្រោមសំបុត្រត្រូវបានឲ្យអនុវត្ត ក្នុងអំឡុងពេលដែលបានកំណត់ជាក់លាក់ (ការលក់ឡាយឡុងដោយស្រោមសំបុត្រក្នុងអំឡុងពេលកំណត់)

បានសេចក្តីថា បង្កើតអំឡុងពេលប្រមាណ 1សប្តាហ៍សំរាប់ការលក់ឡាយឡុងដោយស្រោមសំបុត្រ បន្ទាប់មក គឺកាលបរិច្ឆេទបើកស្រោមសំបុត្រ ហើយបន្ទាប់មកទៀត គឺកាលបរិច្ឆេទនៃការលក់។ គឺអនុវត្តដោយវិធីបើកកាលបរិច្ឆេទដោយឡែកពីគ្នា និងដោយចន្លោះពេលគ្នាប្រមាណមួយសប្តាហ៍។

# 2－2 ការលក់

លេខសំណុំរឿង●●

## ដីកាសម្រេចអនុវត្តការលក់

1 វិធីលក់ : លក់ឡាយឡុងដោយស្រោមសំបុត្រក្នុងអំឡុងពេលកំណត់

អំឡុងពេលលក់ឡាយឡុងដោយស្រោមសំបុត្រ : ចាប់ពីថ្ងៃទី 21 ខែ កុម្ភៈឆ្នាំ 2017 រហូតដល់ម៉ោង 5 ល្ងាច ថ្ងៃទី 28 ខែ កុម្ភៈ ឆ្នាំ 2017

កាលបរិច្ឆេទបើកស្រោមសំបុត្រ : ម៉ោង10:00 ព្រឹកថ្ងៃទី 7 ខែមីនា ឆ្នាំ2017

ទីកន្លែងបើកស្រោមសំបុត្រ : ●● សាលាដំបូងរាជធានីភ្នំពេញ

កាលបរិច្ឆេទចេញដីកាសម្រេចការលក់ : ម៉ោង10:00 ព្រឹកថ្ងៃទី 14 ខែមីនា ឆ្នាំ2017

(តទៅទំព័របន្ទាប់)

# 2－2 ការលក់

(តពីទំព័រមុន)

2 ការធានាលើសំណើទិញ
ធានាដោយវិធីដាក់ជូនតុលាការនូវចំនួនប្រាក់ដែលមានចំនួនស្មើនឹងចំនួន1ភាគ10នៃតម្លៃលក់អប្បបរមា ។

ថ្ងៃទី 20 ខែ កុម្ភៈ ឆ្នាំ2017
សាលាដំបូងរាជធានីភ្នំពេញ ចៅក្រម YUKAWA Ryo

# 2－2 ការលក់

ដើម្បីបង្ការការមិនបង់ថ្លៃលក់របស់អ្នកទិញ ជនដែលបម្រុងនិងធ្វើសំណើទិញអចលនវត្ថុ ត្រូវដាក់ប្រាក់ទៅតុលាការ ជាប្រាក់ធានាដែលមានចំនួនស្មើនិងចំនួន1ភាគ10 នៃតម្លៃលក់អប្បបរមា (ឬចំនួនប្រាក់ដែលតុលាការអនុវត្តបានកំណត់)។ (មាត្រា437 កថាខណ្ឌទី1)

ក្នុងករណីបើបានក្លាយជាអ្នកទិញក្នុងតម្លៃអតិបរមា ប្រាក់ធានានេះនិងត្រូវគិតបញ្ចូលក្នុងថ្លៃលក់។ (មាត្រា447 កថាខណ្ឌទី2)ក្នុងករណីបើមិនបានក្លាយជាអ្នកទិញក្នុងតម្លៃអតិបរមាទេ ក្រោយពេលបញ្ចប់ការលក់ ប្រាក់ធានានឹងត្រូវបានសងមកវិញ។ (មាត្រា 437 កថាខណ្ឌទី2 )

# 2－2 ការលក់

ការងារជាក់ស្តែងនៃការលក់ ប្រគល់ឲ្យអាជ្ញាសាលាជាអ្នកអនុវត្ត ប៉ុន្តែ បន្ទាប់ពីនោះមក តុលាការអនុវត្តត្រូវបើកកាលបរិច្ឆេទដើម្បីចេញដីកាសម្រេចអនុញ្ញាត(ឬមិនអនុញ្ញាត) ឲ្យលក់ ចំពោះអ្នកទិញក្នុងតម្លៃអតិបរមាដែលកំណត់ដោយអាជ្ញាសាលា។
(មាត្រា440 កថាខណ្ឌទី1)

ស្តីពីដីកាសម្រេចនេះ ប្រសិនបើពុំមានចំណុចពិសេសដែលត្រូវបានកំណត់ដោយច្បាប់ទេ តុលាការអនុវត្តត្រូវចេញដីកាសម្រេចអនុញ្ញាតឲ្យលក់។(មាត្រា 442 កថាខណ្ឌទី1)

# 2－2 ការលក់

<ករណីលើកលែង>ករណីដែលតុលាការអនុវត្តត្រូវចេញ

ដីកាសម្រេចមិនអនុញ្ញាតឲ្យលក់ (មាត្រា442 កថាខណ្ឌទី2)

ក－មិនត្រូវចាប់ផ្តើម ឬបន្តនីតិវិធីនៃការលក់ដោយបង្ខំ។

ខ－អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ពុំមានលក្ខណសម្បត្តិ ឬសមត្ថភាពដើម្បីទិញអចលនវត្ថុ ឬអ្នកតំណាងរបស់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមាពុំមានសិទ្ធិនោះ។

# 2－2 ការលក់

<ករណីលើកលែង>ករណីដែលតុលាការអនុវត្តត្រូវចេញដីកាសម្រេចមិនអនុញ្ញាតឲ្យលក់(មាត្រា442កថាខណ្ឌទី2)

គ – មានសេចក្តីស្នើសុំកុំឲ្យអនុញ្ញាតការលក់ ដែលយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៤៩៥ (ការស្នើសុំកុំឲ្យអនុញ្ញាតការលក់ជាអាទិ៍ក្នុងករណីដែលអចលនវត្ថុ ត្រូវបានខូចខាត) នៃក្រមនេះ។

ឃ – មានកំហុសធ្ងន់ធ្ងរនៅក្នុងនីតិវិធីនៃដីកាសម្រេចកំណត់តម្លៃអប្បបរមា។

ង – មានកំហុសធ្ងន់ធ្ងរនៅក្នុងនីតិវិធីនៃការលក់។

# 2－2 ការលក់

លេខសំណុំរឿង●●

**ដីកាសម្រេចអនុញ្ញាតការលក់**

អាសយដ្ឋាន ○○○
ឈ្មោះ UCHIYAMA Jun

អនុញ្ញាតការលក់អចលនវត្ថុ ដែលមានកំណត់ក្នុងឯកសារភ្ជាប់ស្តីពីបញ្ជីវត្ថុ ដោយហេតុថាជនដែលបានកំណត់ខាងលើ បានធ្វើសំណើទិញក្នុងតម្លៃអតិបរមា ដែលមានចំនួនទឹកប្រាក់ ●●ដុល្លារអាមេរិក។

ថ្ងៃទី 21ខែកុម្ភៈ ឆ្នាំ2017
សាលាដំបូងរាជធានីភ្នំពេញ ចៅក្រម YUKAWA Ryo

# 2－2 ការលក់

ប្រសិនបើមានឧបាស្រ័យចំពោះដីកាសម្រេចអនុញ្ញាត( ឬមិនអនុញ្ញាត) ឲ្យលក់ជនដែលពាក់ព័ន្ធនិងផលប្រយោជន៍ អាចប្តឹងជំទាស់ បាន លុះត្រាតែក្នុងករណីដែលដីកាសម្រេចនោះ បណ្តាលឲ្យមានខូចខាតដល់សិទ្ធិរបស់ខ្លួន ។

（មាត្រា 444 កថាខណ្ឌទី1 ）

※ បណ្តឹងជំទាស់ចំពោះដីកាសម្រេចអនុញ្ញាតឲ្យលក់ ត្រូវយកហេតុដូចបានកំណត់ក្នុងចំណុចនីមួយៗនៃកថាខណ្ឌទី ២នៃមាត្រា៤៨២ (ការអនុញ្ញាត ឬមិនអនុញ្ញាតឲ្យលក់)នៃក្រមនេះ ឬកំហុសធ្ងន់ធ្ងរនៅក្នុងនីតិវិធីនៃដីកាសម្រេចអនុញ្ញាតឲ្យលក់នោះ មកធ្វើជាមូលហេតុ ។(មាត្រា 444 កថាខណ្ឌទី2)

# [យោង]ការធ្វើឧបាស្រ័យ

បណ្ដឹងជំទាស់(មាត្រា345)

- មាត្រានេះចែងអំពីការធ្វើឧបាស្រ័យ ចំពោះដីកាសម្រេចដែលលុបចោលនីតិវិធីនៃការការអនុវត្តដោយបង្ខំ ។

<u>ការតវ៉ាចំពោះការអនុវត្ត</u> (មាត្រា344)

- ចំពោះការចាត់ចែងការអនុវត្តរបស់តុលាការអនុវត្ត <u>ដែលមិនអាចប្ដឹងជំទាស់បាន</u> អាចតវ៉ាទៅតុលាការអនុវត្តបាន ដោយអះអាងអំពីការបំពានលើនីតិវិធីនោះ។
- ការសម្រេចសេចក្ដីត្រូវបានធ្វើឡើយដោយដីកាសម្រេច ដោយគ្មានការកម្រិតអំឡុងពេល។
- ពុំមែនជាបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ទេ គឺជាការទាមទារសុំឲ្យតុលាការជម្រះក្ដីដដែលនោះ ធ្វើការពិចារណាឡើងវិញ។
- ជាគោលការណ៍មិនអាចធ្វើឧបាស្រ័យចំពោះ ការតវ៉ាចំពោះការអនុវត្តបានឡើយ។

# 2－2 ការលក់

＜នីតិវិធីដែលត្រូវធ្វើនៅពេលមិនអាចលក់បាន＞

បើយល់ឃើញថាចាំបាច់តុលាការអនុវត្តអាចផ្លាស់ប្តូរតម្លៃលក់អប្បបរមាបាន ។(មាត្រា432 កថាខណ្ឌទី2)

※នៅក្នុងការងារជាក់ស្តែងនៃជប៉ុន តុលាការអនុវត្តសួរមតិយោបល់របស់អ្នកវាយតម្លៃ ហើយផ្លាស់ប្តូរតម្លៃលក់ដោយឆន្ទានុសិទ្ធិ។

រឹបអូស

1－1 ដាក់ពាក្យសុំ
1－2 ដីកាសម្រេចចាប់ផ្ដើម
1－3 រឹបអូស
1－4 ទាមទារឲ្យចែកចំណែក

លក់

2－1 ស្រាវជ្រាវ
2－2 លក់
**2－3 អានុភាព**

ចែកចំណែក

3－1 រៀបចំ
3－2 ចែកចំណែក

# 2－3 អានុភាព

បើដីកាសម្រេចអនុញ្ញាតឲ្យលក់បានចូលជាស្ថាពរ អ្នកទិញត្រូវបង់ថ្លៃលក់ទៅតុលាការអនុវត្ត នៅមុនពេលដែលតុលាការអនុវត្តបានកំណត់ ។ ពេលកំណត់នេះ ត្រូវស្ថិតនៅក្នុងអំឡុងពេល១ (មួយ)ខែ ចាប់ពីថ្ងៃដែលដីកាសម្រេចអនុញ្ញាតឲ្យលក់បានចូលជាស្ថាពរ ។(មាតា447កថាខណ្ឌទី1)

※ ចំនួនទឹកប្រាក់ដែលអ្នកទិញបានដាក់ដើម្បីធានាលើសំណើទិញត្រូវគិតបញ្ចូលក្នុងថ្លៃលក់។(មាត្រា447 កថាខណ្ឌទី2)

# 2－3 អានុភាព

លេខសំណុំរឿង●●

សេចក្ដីកំណត់នៃកំណត់ពេលដែលត្រូវបង់ថ្លៃលក់

ចំពោះអចលនវត្ថុដែលមានកំណត់នៅក្នុងឯកសារភ្ជាប់ស្ដីពីបញ្ជីវត្ថុ តុលាការកំណត់ថា កំណត់ពេលដែលត្រូវបង់ថ្លៃលក់គឺត្រឹមល្ងាចម៉ោង 1:00 ថ្ងៃទី1ខែមីនា ឆ្នាំ2017 ។

ថ្ងៃទី 21 ខែកុម្ភៈឆ្នាំ 2017

សាលាដំបូងរាជធានីភ្នំពេញ ចៅក្រម YUKAWA Ryo

# 2－3 អានុភាព

＜ក្នុងករណីថ្លៃលក់មិនត្រូវបានបង់(មាត្រា451)＞

បើអ្នកទិញមិនបានបង់ថ្លៃលក់ទេ ដីកាសម្រេចអនុញ្ញាតឲ្យលក់នោះ នឹងបាត់បង់អានុភាព។

ក្នុងករណីនេះ អ្នកទិញមិនអាចទាមទារឲ្យសងទឹកប្រាក់ដែលខ្លួនបានដាក់ជាការធានាលើសំណើទិញបានទេ។

តុលាការអនុវត្តត្រូវអនុវត្តការលក់ដោយបង្ខំសាជាថ្មី។

# 2－3 អានុភាព

＜ក្នុងករណីថ្លៃលក់ត្រូវបានបង់(មាត្រា447 កថាខណ្ឌទី4)＞

អ្នកទិញធ្វើលទ្ធកម្មនូវអចលនវត្ថុនៅពេលដែលខ្លួនបានបង់ថ្លៃលក់ហើយ។

# 2－3 អានុភាព

＜ក្នុងករណីថ្លៃលក់ត្រូវបានបង់ (មាត្រា448)＞

ប្រសិនបើអ្នកទិញបានបង់ថ្លៃលក់ហើយ ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជី និងលុបការចុះបញ្ជីនូវចំណុចដូចកំណត់ខាងក្រោមនេះ ។

ក－ ការចុះបញ្ជីអំពីការផ្ទេរសិទ្ធិដែលអ្នកទិញបានធ្វើលទ្ធកម្ម។

ខ－ការលុបការចុះបញ្ជីអំពីលទ្ធកម្មនូវសិទ្ធិដែលបានរលត់ ឬ សិទ្ធិដែលបានបាត់បង់អានុភាពដោយការលក់។

→ ចំពោះនីតិវិធីលំអិត សូមមើល「ប្រការ」ទី 9 និងទី25 ជាអាទ៍

※សូមមើលឯកសារនៃសិក្ខាសាលានាខែកក្កដា ឆ្នាំ2015

# 2－3 អានុភាព

តុលាការអនុវត្តអាចចេញដីកាសម្រេចបង្គាប់ឲ្យកូនបំណុលនៃការអនុវត្ត ឬអ្នកកាន់កាប់អចលនវត្ថុ ប្រគល់អចលនវត្ថុនោះទៅឲ្យអ្នកទិញ តាមពាក្យសុំរបស់អ្នកទិញដែលបានបង់ថ្លៃលក់ហើយ។(មាត្រា450 កថាខណ្ឌទី1)

※បើហួសអំឡុងពេល 6 ខែគិតចាប់ពីថ្ងៃដែលអ្នកទិញបានបង់ថ្លៃលក់ហើយ អ្នកទិញនោះពុំអាចដាក់ពាក្យសុំបានទេ។(មាត្រា450 កថាខណ្ឌទី2)

# 2－3 អានុភាព

លេខសំណុំរឿង△

**ដីកាសម្រេចបង្គាប់ឲ្យប្រគល់អចលនវត្ថុ**

ភាគី (សូមរំលងចោល)

ដោយហេតុថា អ្នកដែលបានទិញនិងបានបង់ថ្លៃលក់នូវអចលនវត្ថុដូចមានកំណត់ក្នុងឯកសារភ្ជាប់ស្តីពីបញ្ជីវត្ថុ នៅក្នុងរឿងក្តីស្តីពីការលក់ដោយបង្ខំនូវអចលនវត្ថុនៃតុលាការនេះ (លេខសំណុំរឿង●●) បានដាក់ពាក្យស្នើសុំបង្គាប់ឲ្យប្រគល់អចលនវត្ថុ តុលាការយល់ឃើញថាពាក្យសុំនេះមានមូលហេតុត្រឹមត្រូវ ហេតុនេះចេញដីការសម្រេចដូចតទៅ។

(តទៅទំព័របន្ទាប់)

# 2－3 អនុភាព

(តពីទំព័រមុន)

សេចក្ដីសម្រេចបញ្ជាប់

បង្គាប់ឲ្យភាគីម្ខាងទៀតនៃការស្នើសុំឈ្មោះ ○○ ប្រគល់
អចលនវត្ថុដែលមានកំណត់ក្នុងឯកសារភ្ជាប់ស្ដីពីបញ្ជីវត្ថុ
ទៅអ្នកស្នើសុំឈ្មោះ ■■ ។

ថ្ងៃទី 21 ខែកុម្ភៈ ឆ្នាំ2017
សាលាដំបូងរាជធានីភ្នំពេញ ចៅក្រម YUKAWA Ryo

# 2－3 អានុភាព

ការចែកចំណែកនឹងត្រូវបានអនុវត្ត បន្ទាប់ពីថ្លៃលក់ត្រូវបានបង់។

(មាត្រា488 កថាខណ្ឌទី1 ចំណុច គ និងមាត្រា489)

រឹបអូស

↓

លក់

↓

ចែកចំណែក

# «ការចែកចំណែក»គឺ

- យកថ្លៃលក់ដែលបានមកពីការលក់អចលនវត្ថុ ដែលបានរឹបអូស មកបែងចែកឲ្យម្ចាស់បំណុល។

- ក្នុងករណីដែលម្ចាស់បំណុលមានតែម្នាក់ ក្រោយពេលបានបង់សិទ្ធិ លើបំណុលឲ្យម្ចាស់បំណុលហើយ ផ្តល់ប្រាក់ដែលនៅសេសសល់ ឲ្យទៅកូនបំណុលនៃការអនុវត្ត ។

- ក្នុងករណីដែលម្ចាស់បំណុលមានច្រើននាក់ ហើយប្រាក់ដែលបាន មកពីការលក់ មិនគ្រប់ចំនួនសរុបនៃចំនួនទឹកប្រាក់សិទ្ធិលើបំណុល ទេ ត្រូវបែងចែកតាមការព្រមព្រៀង ឬតាមការកំណត់នៃច្បាប់។

**រឹបអូស**

1－1 ដាក់ពាក្យសុំ
1－2 ដីកាសម្រេចចាប់ផ្តើម
1－3 រឹបអូស
1－4 ទាមទារឲ្យចែកចំណែក

↓

**លក់**

2－1 ស្រាវជ្រាវ
2－2 លក់
2－3 អានុភាព

↓

**ចែកចំណែក**

<u>3－1 រៀបចំ</u>
3－2 ចែកចំណែក

# 3－1 ការរៀបចំការចែកចំណែក

ប្រាក់ដែលកំណត់ដូចខាងក្រោមនេះ ត្រូវចាត់ជាថ្លៃលក់ សម្រាប់ការចែកចំណែក។ (មាត្រា452 កថាខណ្ឌទី1)

- ថ្លៃលក់អចលនវត្ថុ ។
- ប្រាក់ដែលបានបង់ដើម្បីធានាការមិនបង់ថ្លៃទិញ ដែលអ្នកទិញពុំអាចទាមទារឲ្យសងមកវិញបាន។

# ３－１ ការរៀបចំការចែកចំណែក

តុលាការអនុវត្តត្រូវអនុវត្តការចែកចំណែកចំពោះ「ម្ចាស់បំណុលដែលត្រូវទទួលចំណែក」។(មាត្រា453)

# 3－1 ការរៀបចំការចែកចំណែក

ម្ចាស់បំណុលដែលត្រូវទទួលចំណែក (មាត្រា453)

1 ម្ចាស់បំណុលដែលបានដាក់ពាក្យសុំការលក់ដោយបង្ខំ ឬការលក់ដោយបង្ខំដែលជាការអនុវត្តឯកសិទ្ធិទូទៅ រហូតដល់កំណត់ពេលចុងក្រោយសម្រាប់ការទាមទារឲ្យចែកចំណែក។

2 ម្ចាស់បំណុលដែលបានទាមទារឲ្យចែកចំណែក រហូតដល់ពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឲ្យចែកចំណែក ។

3 ម្ចាស់បំណុលដែលបានចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន នៅមុនការចុះបញ្ជីអំពីការរឹបអូសដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំដំបូង ។

→ ដើម្បីញែកឲ្យស្រួលយល់ នឹងមានដូចទំព័របន្ទាប់តទៅនេះ។

# 3－1 ការរៀបចំការចែកចំណែក

1 ជនដែលបានដាក់ពាក្យសុំការលក់ដោយបង្ខំរហូតដល់កំណត់ពេលចុងក្រោយសម្រាប់ការទាមទារឲ្យចែកចំណែក។

1－1 ដាក់ពាក្យសុំដោយផ្អែកលើលិខិតអនុវត្ត

1－2 ដាក់ពាក្យសុំជាការអនុវត្តសិទ្ធិប្រាតិភោគ

# 3－1 ការរៀបចំការចែកចំណែក

2 ជនដែលបានទាមទារឲ្យចែកចំណែក រហូតដល់ពេលកំណត់ចុងក្រោយ សម្រាប់ការទាមទារឲ្យចែកចំណែក ។

<ជនដែលអាចទាមទារឲ្យចែកចំណែក(មាត្រា426 កថាខណ្ឌទី1)>

2－1 ជនដែលមានលិខិតអនុវត្ត (មាត្រា354 និងមាត្រា 350 កថាខណ្ឌទី2)

2－2 ម្ចាស់បំណុលដែលបានចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន នៅក្រោយពេញចុះបញ្ជីអំពីការរឹបអូស ដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំ ។

2－3 ជនដែលមានឯកសិទ្ធិទូទៅ(សូមមើលមាត្រា 783 ក្រមរដ្ឋប្បវេណី។ ចាំបាច់ត្រូវបញ្ជាក់ដោយឯកសារ )

# 3－1 ការរៀបចំការចែកចំណែក

**3** ម្ចាស់បំណុលដែលបានចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន នៅមុន「ការចុះបញ្ជីអំពីការរឹបអូសដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំដំបូង 」។

※ ម្ចាស់បំណុលដែលបានចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ននៅក្រោយពេល 「ចុះបញ្ជីអំពីការរឹបអូស」 ត្រូវធ្វើការទាមទារឲ្យចែកចំណែកសិន ទើបអាចទទួលការចែកចំណែកបាន។ (មាត្រា426 កថាខណ្ឌទី1 ចំណុច ខ)

| | | ទាមទារឲ្យចែកចំណែក | ចែកចំណែក |
|---|---|---|---|
| ម្ចាស់បំណុលនៃការអនុវត្ត | | × (មិនតម្រូវ) | ○ |
| ម្ចាស់បំណុលដែលបានដាក់ពាក្យសុំលក់ដោយបង្ខំ (ក្រៅពីម្ចាស់បំណុលនៃការអនុវត្ត) | | × (មិនតម្រូវ) | ○ |
| ម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគ | មុន「ចុះបញ្ជី」 | × (មិនអាច) 【ប្រយ័ត្ន】 | × |
| | ក្រោយ「ចុះបញ្ជី」 | × (មិនអាច) | × |
| ជនដែលមានឯកសិទ្ធិទូទៅ | | ○ | ○ |
| ម្ចាស់បំណុលរឹបអូសជាបណ្តោះអាសន្ន | មុន「ចុះបញ្ជី」 | × (មិនតម្រូវ) | ○ |
| | ក្រោយ「ចុះបញ្ជី」 | ○ | ○ |
| ម្ចាស់បំណុលទូទៅ | មានលិខិតអនុវត្ត | ○【ប្រយ័ត្ន】 | ○ |
| | គ្មានលិខិតអនុវត្ត | × (មិនអាច) | × |

※ពាក្យ「ចុះបញ្ជី」នៅក្នុងតារាងនេះសំដៅទៅលើការចុះបញ្ជីរឹបអូស ដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ

# 3－1 ការរៀបចំការចែកចំណែក

【ចំណុចដែលត្រូវប្រុងប្រយ័ត្ន 】

ម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគ ដែលនឹងបន្តមានអត្ថិភាពក្រោយការលក់ (ម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគដែលត្រូវបានចុះបញ្ជី នៅមុនការ「ចុះបញ្ជី」អំពីការរឹបអូស ) ទោះបីជាមានលិខិតអនុវត្តក៏ដោយ ក៏មិនអាចទទួលការចែកចំណែកបានឡើយ(ម្យ៉ាងទៀត ក៏មិនអាចទាមទារឲ្យចែកចំណែកបានដែរ)។

→ដើម្បីអាចទទួលការចែកចំណែកបាន ត្រូវដាក់ពាក្យសុំការលក់ដោយបង្ខំដែលជាការអនុវត្តសិទ្ធិប្រាតិភោគដោយឆន្ទៈរបស់ខ្លួននៅមុនពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឲ្យចែកចំណែក។
(សូមមើលមាត្រា 422 កថាខណ្ឌទី3 ចំណុច ខ)

# 3－1 ការរៀបចំការចែកចំណែក

តុលាការអនុវត្តដែលត្រូវចែកចំណែក ត្រូវកំណត់កាលបរិច្ឆេទនៃការចែកចំណែក ហើយផ្តល់ដំណឹងអំពីពេលវេលា និងទីកន្លែងនោះ ទៅម្ចាស់បំណុលដែលត្រូវទទួលការចែកចំណែកនិងកូនបំណុល ។ (មាត្រា488 កថាខណ្ឌទី 1)

**រឹបអូស**

1–1 ដាក់ពាក្យសុំ
1–2 ដីកាសម្រេចចាប់ផ្តើម
1–3 រឹបអូស
1–4 ទាមទារឲ្យចែកចំណែក

**លក់**

2–1 ស្រាវជ្រាវ
2–2 លក់
2–3 អានុភាព

**ចែកចំណែក**

3–1 រៀបចំ
**<u>3–2 ចែកចំណែក</u>**

# 3－2 ការចែកចំណែក

វិធីចែកចំណែកមាន 2 ។

①ការចែកចំណែកដោយមិនចាំបាច់ផ្អែកលើតារាងចែកចំណែក។
(មាត្រា489 កថាខណ្ឌទី1 វាក្យខណ្ឌទី 2 និងកថាខណ្ឌទី2)

②ការចែកចំណែកដោយផ្អែកលើតារាងចែកចំណែក ដែលបានធ្វើនៅកាលបរិច្ឆេទនៃការចែកចំណែក ។
(មាត្រា489 កថាខណ្ឌទី1 វាក្យខណ្ឌទី1)

# 3－2 ការចែកចំណែក

①ការចែកចំណែកដែលមិនផ្អែកលើតារាងចែកចំណែក
（ មាត្រា489 កថាខណ្ឌទី1វាក្យខណ្ឌទី2 និងកថាខណ្ឌទី2)

ក្នុងករណីដែលម្ចាស់បំណុលមានតែម្នាក់
ឬ
ក្នុងករណីដែលម្ចាស់បំណុលមានច្រើននាក់ ហើយទឹកប្រាក់ដែលត្រូវបំពេញការចែកចំណែកនោះ អាចសងសព្វគ្រប់ចំពោះសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនីមួយៗ ព្រមទាំងសោហ៊ុយសម្រាប់ការអនុវត្ត។

# 3－2 ការចែកចំណែក

【 ឧទាហរណ៍ជាក់ស្តែង 】

ម្ចាស់បំណុលដែលអាចទទួលការចែកចំណែក(ចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល)

A (4 លានរៀល )
B (3 លានរៀល )

ចំនួនទឹកប្រាក់សរុបដែលត្រូវអនុវត្តការចែកចំណែកគឺ 9លានរៀល ។

# 3－2 ការចែកចំណែក

【 ឧទាហរណ៍ជាក់ស្តែង 】

ម្ចាស់បំណុលដែលអាចទទួលការចែកចំណែក(ចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល)

A (4 លានរៀល ) → 4 លានរៀល
B (3 លានរៀល) → 3 លានរៀល

※ប្រគល់2លានរៀល (ប្រាក់សេសសល់) ចំពោះកូនបំណុល ។

# 3－2 ការចែកចំណែក

② ចែកចំណែកដោយផ្អែកលើតារាងចែកចំណែក ដែលបានធ្វើនៅកាលបរិច្ឆេទចែកចំណែក។ (មាត្រា489 កថាខណ្ឌទី1 វាក្យខណ្ឌទី 1)

ធ្វើតារាងចែកចំណែកនៅកាលបរិច្ឆេទនៃការចែកចំណែក។ (មាត្រា490)

នៅកាលបរិច្ឆេទចែកចំណែកត្រូវកោះហៅ「ម្ចាស់បំណុលដែលត្រូវទទួលចំណែក」(មាត្រា453) និងកូនបំណុលនៃការអនុវត្ត។(មាត្រា490 កថាខណ្ឌទី2 ចំណុច គ)

# 3－2 ការចែកចំណែក

តុលាការអនុវត្តត្រូវធ្វើសេចក្តីព្រៀងនៃតារាងចែកចំណែកដោយផ្អែកលើលិខិតគណនាដែលត្រូវបានដាក់ដោយម្ចាស់បំណុលម្នាក់ៗជាមុន ។

នៅកាលបរិច្ឆេទចែកចំណែក  ពាក់ព័ន្ធនិងការធ្វើតារាងចែកចំណែក តុលាការអាចសួរម្ចាស់បំណុលនិងកូនបំណុលនៃការអនុវត្តដែលបង្ហាញខ្លួន ហើយអាចធ្វើការពិនិត្យភស្តុតាងជាឯកសារដែលអាចធ្វើការពិនិត្យភ្លាមៗបាននៅកាលបរិច្ឆេទនៃការចែកចំណែក(មាត្រា490 កថាខណ្ឌទី 3)

# 3－2 ការចែកចំណែក

ចំណុចដែលត្រូវសរសេរក្នុងតារាងចែកចំណែក(មាត្រា490 កថាខណ្ឌទី4 ចំណុច គ)

- ចំនួនទឹកប្រាក់បានមកពីការលក់។
- អំពីម្ចាស់សិទ្ធិលើបំណុលម្នាក់ៗ ។

ប្រាក់ដើម ការប្រាក់ ការប្រាក់ឃើតយ៉ាវនៃសិទ្ធិលើបំណុល ជាអាទ៍ ។

ចំនួនទឹកប្រាក់នៃសោហ៊ុយអនុវត្ត។

<u>លំដាប់នៃការបែងចែកនិងចំនួនទឹកប្រាក់ ។</u>

# 3－2 ការចែកចំណែក

លំដាប់និងចំនួនទឹកប្រាក់នៃការចែកចំណែក ( មាត្រា490 កថាខណ្ឌទី5)

・ នៅកាលបរិច្ឆេទចែកចំណែក ក្នុងករណីដែលកិច្ចព្រមព្រៀងបានសម្រេចឡើងរវាងម្ចាស់បំណុលគ្រប់រូប នោះត្រូវសរសេរតាមការព្រមព្រៀង។

・ ក្នុងករណីដែលកិច្ចព្រមព្រៀងមិនអាចសម្រេចបាន ត្រូវសរសេរតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ច្បាប់ដែលទាក់ទងនិងពាណិជ្ជកម្ម ឬ ច្បាប់ផ្សេងទៀត។

→ ការសម្រេចដោយកិច្ចព្រមព្រៀងពុំសូវមានទេ ភាគច្រើនគឺចែកចំណែកតាមបញ្ញត្តិនៃច្បាប់ ។ (ឧ.ជាក់ស្តែង①និង②) នៅទំព័របន្ទាប់)

# 3－2 ការចែកចំណែក

【ឧ.ជាក់ស្តែង①=ប្រសិនបើរវាងម្ចាស់បំណុលមានល័ក្ខខ័ណ្ឌស្មើគ្នា】

ម្ចាស់បំណុលដែលអាចទទួលកាចែកចំណែក(ចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល)

A( 4 លានរៀល ) សិទ្ធិលើបំណុលទូទៅ
B( 6 លានរៀល ) សិទ្ធិលើបំណុលទូទៅ
C( 8 លានរៀល ) សិទ្ធិលើបំណុលទូទៅ

ចំនួនទឹកប្រាក់សរុបដែលត្រូវអនុវត្តការចែកចំណែកគឺ9លានរៀល។

# 3－2 ការចែកចំណេក

【ឧ.ជាក់ស្តែង①=ប្រសិនបើរវាងម្ចាស់បំណុលមានល័ក្ខខ័ណ្ឌស្មើគ្នា】

ចំនួនប្រាក់ចំណែក

A（ 4 លានរៀល ） → 2 លានរៀល
B（ 6 លានរៀល ） → 3 លានរៀល
C（ 8 លានរៀល ） → 4 លានរៀល

→យក9 លានរៀលបែងចែកស្របតាមសមាមាត្រនៃទឹកប្រាក់សិទ្ធិលើបំណុល(4:6:8=2:3:4)

※ ពុំមានប្រាក់សេសសល់ដែលត្រូវបង់ឲ្យកូនបំណុលនៃការអនុវត្តទេ។

# 3－2 ការចែកចំណែក

【ឧ.ជាក់ស្តែង ②=ប្រសិនបើរវាងម្ចាស់បំណុលមានល័ក្ខខ័ណ្ឌអាទិភាព】

ម្ចាស់បំណុលដែលអាចទទួលការចែកចំណែក(ចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល)

A( 4 លានរៀល ) សិទ្ធិលើបំណុលទូទៅ
B( 6 លានរៀល ) ជនដែលមានឯកសិទ្ធិទូទៅ
C( 8 លានរៀល ) សិទ្ធិលើបំណុលទូទៅ

ចំនួនទឹកប្រាក់សរុបដែលត្រូវអនុវត្តការចែកចំណែកគឺ9 លានរៀល។

# 3－2 ការចែកចំណែក

【 ឧ.ជាក់ស្តែង ②=ប្រសិនបើវាម្ចាស់បំណុលមានល័ក្ខខ័ណ្ឌអាទិភាព 】

ចំនួនប្រាក់ចំណែក

A( 4 លានរៀល) → ②1 លានរៀល
B( 6 លានរៀល ) → ①6 លានរៀល
C( 8 លានរៀល ) → ②2 លានរៀល

→ក្រោយពេលបានចែកចំណែកសិទ្ធិលើបំណុលទាំងអស់របស់ម្ចាស់បំណុល B ដែលត្រូវផ្តល់អាទិភាពរួចហើយ ទើបយកចំនួនប្រាក់សេសសល់(9−6=3)ចែកតាមសមាមាត្រានៃចំនួនប្រាក់សិទ្ធិលើបំណុល(4:8=1:2)។

※ពុំមានប្រាក់សេសសល់ដែលត្រូវបង់ឲ្យកូនបំណុលនៃការអនុវត្តទេ។

# 3－2 ការចែកចំណែក

ក្នុងករណីមានឧបាស្រ័យចំពោះសិទ្ធិលើបំណុល ឬចំនួនប្រាក់ចំណែករបស់ម្ចាស់បំណុលម្នាក់ៗ ដែលត្រូវបានសរសេរលើតារាងចែកចំណែកម្ចាស់បំណុលនិងកូនបំណុលនៃការអនុវត្តអាចថ្លែងសេចក្តីតវ៉ាបាន នៅកាលបរិច្ឆេទនៃការចែកចំណែក។ (មាត្រា491 កថាខណ្ឌទី1)

↓ ក្នុងអំឡុងពេលមួយសប្តាហ៍ចាប់ពីកាលបរិច្ឆេទនៃការចែកចំណែក

ត្រូវដាក់ពាក្យបណ្តឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក(មាត្រា 492 កថាខណ្ឌទី1)

# 3－2 ការចែកចំណែក

តុលាការដែលត្រូវអនុវត្តការចែកចំណែក ត្រូវធ្វើការចែកចំណែកតែផ្នែកដែលគ្មានការតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក។ (មាត្រា 491 កថាខណ្ឌទី2)

ដោយហេតុនេះហើយ ប្រហែលជាអាចនឹងមានកូនបំណុលទុច្ចរិតមានគំនិត「គ្មានមូលដ្ឋានភស្តុតាងអ្វីទេ ប៉ុន្តែឡើងថ្លែងសេចក្តីតវ៉ាចោលសិន」ជាអាទិ៍ ដើម្បីរាំងការអនុវត្តនៃការចែកចំណែក ។

ដើម្បីការពារហេតុការណ៍ប្រភេទនេះ បើមិនដាក់ពាក្យបណ្តឹងក្នុងអំឡុងពេលមួយសប្តាហ៍ទេ ត្រូវចាត់ទុកថាការតវ៉ាបានដកវិញ។ (មាត្រា 492 កថាខណ្ឌទី 3)

# 3－2 ការចែកចំណែក

ដោយឡែក ប្រសិនបើកូនបំណុលនៃការអនុវត្តសុំឧបាស្រ័យ ហើយក្នុងករណីបើយកម្ចាស់បំណុលដែលមានលិខិតអនុវត្តជាភាគីម្ខាងទៀត ឧបាស្រ័យនោះនឹងក្លាយជាការតវ៉ាចំពោះអត្ថិភាពនៃសិទ្ធិ និងខ្លឹមសារដែលត្រូវបានសរសេរលើលិខិតអនុវត្ត ហេតុនេះត្រូវដាក់ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារ។ (មាត្រា493 កថាខណ្ឌទី 1 និងមាត្រា 363)

※ចំពោះករណីផ្សេងទៀត ដូចគ្នានិងការធ្វើឧបាស្រ័យចំពោះម្ចាស់បំណុលដទៃទៀតដែរ ត្រូវដាក់ពាក្យបណ្តឹតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក។(មាត្រា493 កថាខណ្ឌទី2 )

# 【យោខ】ការផ្អាកនិងការលុបចោលការអនុវត្តដោយបង្ខំ

ក្នុងករណីដែលនីតិវិធីអនុវត្តដោយបង្ខំដែលផ្អែកលើសាលក្រម ឬសាលដីកាដែលមានខ្លឹមសារថា「បង្គាប់ឲ្យ Y បង់ 1ម៉ឺនដុល្លារអាមេរិកទៅ X」ត្រូវបានចាប់ផ្តើមទៅតាមសភាពការណ៍ អាចនឹងមានជនដែលទទួលការខូចប្រយោជន៍ដាក់ពាក្យបណ្តឹងឧបាស្រ័យអំពីដំណើរការនៃការអនុវត្តដោយបង្ខំនោះ។

នេះជាករណីលើកលែងទេ ក៏ប៉ុន្តែតើនឹងអាចកើតមានសភាពការណ៍យ៉ាងដូចម្តេចខ្លះ ?

# បណ្ដឹងតវ៉ាចំពោះការទាមទារ(មាត្រា363)

Y



ដោយសារការសម្រេចសេចក្ដីបង្គាប់ឲ្យបង់ 1ម៉ឺន ដុល្លារអាមេរិកទៅ X បានចូលជាស្ថាពរ ខ្ញុំក៏បាន សង 1ម៉ឺនដុល្លារអាមេរិក ទៅ X ។

- នេះគឺជាពាក្យបណ្ដឹងដាក់ដោយកូនបំណុលនៃការអនុវត្តដែលមានការតវ៉ា ចំពោះអត្ថិភាពនៃសិទ្ធិទាមទារ ឬខ្លឹមសារដែលត្រូវបានសរសេរលើលិខិតអនុវត្ត។
- មូលហេតុនៃការតវ៉ាចំពោះសាលក្រម ឬសាលដីកាស្ថាពរ ត្រូវបានកម្រិតត្រឹមតែហេតុដែលកើតឡើងនៅក្រោយការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់(មាត្រា363 កថាខណ្ឌទី2 និងមាត្រា194 កថាខណ្ឌទី1)
- ប្រសិនបើការតវ៉ានោះមានមូលហេតុត្រឹមត្រូវ នោះនៅក្នុងសេចក្ដីសម្រេចបញ្ចប់នឹងត្រូវបានបង្ហាញថា មិនអនុញ្ញាតការអនុវត្តដោយបង្ខំដោយផ្អែកតាមលិខិតអនុវត្ត ។

# បណ្ដឹងតវ៉ារបស់តតិយជន (មាត្រា365)




- នេះគឺជាពាក្យបណ្ដឹងដាក់ដោយជនដែលត្រូវបានបំពានសិទ្ធិដោយខុសច្បាប់ ក្នុងករណីដែលការអនុវត្តដោយបង្ខំត្រូវបានធ្វើចំពោះទ្រព្យសម្បត្តិរបស់តតិយជនដែលនៅក្រៅទំហំនៃអានុភាពអនុវត្ត ។
- ប្រសិនបើការតវ៉ានេះត្រូវបានទទួលស្គាល់ នោះនៅក្នុងសេចក្ដីសម្រេចបញ្ចប់នឹងមានបង្ហាញថា មិនអនុញ្ញាតការអនុវត្តលើទ្រព្យសម្បត្តិដែលកំណត់ជាក់លាក់របស់ចុងចម្លើយ ។

# ការដាក់ពាក្យសុំតវ៉ាអំពីការផ្តល់ រូបមន្តអនុវត្ត(មាត្រា362)

Y



នៅក្នុងលិខិតអនុវត្តកំណត់កាលបរិច្ឆេទស្ថាពរថា「នៅពេលដែលថ្ងៃទី22 ខែកុម្ភៈ ឆ្នាំ 2017បានមកដល់…」ក៏ប៉ុន្តែកាលបរិច្ឆេទមិនទាន់បានមកដល់ផង រូបមន្តអនុវត្តត្រូវបានផ្តល់ទៅហើយ។

- នេះគឺជាវិធីសុំឧបាស្រ័យក្នុងករណីដែលការចាត់ចែងទាក់ទងនឹងការផ្តល់រូបមន្តអនុវត្តផ្ទុយនិងច្បាប់។
- ការសម្រេចសេចក្តីត្រូវធ្វើឡើងដោយដីកាសម្រេច (មាត្រា362 កថាខណ្ឌទី2)
- ប្រសិនបើការតវ៉ានេះមានមូលហេតុត្រឹមត្រូវ នោះនៅក្នុងសេចក្តីសម្រេចបញ្ជាប់និងបង្ហាញថា លុបចោលរូបមន្តអនុវត្ត និងមិនអនុញ្ញាតការអនុវត្តដោយបង្ខំដោយផ្អែកលើឯកសារចម្លងយថាភូត នៃលិខិតអនុវត្តដែលត្រូវបានភ្ជាប់ជាមួយរូបមន្តអនុវត្តនោះ។

# ការដាក់ពាក្យសុំតវ៉ាអំពីការផ្តល់រូបមន្តអនុវត្ត(មាត្រា364)

Y



នៅក្នុងលិខិតអនុវត្តមានភ្ជាប់ល័ក្ខខ័ណ្ឌបង្អង់ថា「 ដោយប្តូរនិងការបានទទួលរថយន្តពី X…」 ហើយបានផ្តល់រូបមន្តអនុវត្តពិសេសស្តីពីការបំពេញល័ក្ខខណ្ឌនោះផងៗក៏ប៉ុន្តែ ជាក់ស្តែងខ្ញុំមិនទាន់បានទទួលការប្រគល់រថយន្តពី X នៅឡើយទេ។

- នេះគឺជាពាក្យបណ្តឹងដាក់ដោយកូនបំណុលនៃការអនុវត្ត ក្នុងករណីដែល<u>រូបមន្តអនុវត្តពិសេស</u>ត្រូវបានផ្តល់ តែពុំមានអង្គហេតុ (ល័ក្ខខ័ណ្ឌដែលត្រូវបំពេញជាអាទ៏ )ដែលជាល័ក្ខខណ្ឌនៃការផ្តល់។(មាត្រា356)

- ប្រសិនបើការតវ៉ានេះមានមូលហេតុត្រឹមត្រូវ នោះនៅក្នុងសេចក្តីសម្រេចបញ្ជាប់ នឹងត្រូវបានបង្ហាញថា មិនអនុញ្ញាតការអនុវត្តដោយបង្ខំដែលផ្អែកលើលិខិតអនុវត្តដែលត្រូវបានភ្ជាប់ជាមួយរូបមន្តអនុវត្តនោះ។

# [យោង]ការផ្អាកនិងការលុបចោលការអនុវត្តដោយបង្ខំ

ប្រសិនបើពាក្យបណ្តឹង ឬពាក្យសុំទាំងឡាយនោះ ត្រូវបានទទួលស្គាល់ នៅពេលដែលយកអនុសារសាលក្រម ឬសាលដីកា ឬយកឯកសារចម្លងយថាភូតនៃដីកាសម្រេចទៅដាក់នៅស្ថាប័នអនុវត្ត នោះការអនុវត្តដោយបង្ខំនឹងត្រូវបានផ្អាក ហើយការចាត់ចែងការអនុវត្តដែលបានធ្វើរួចហើយក៏ត្រូវបានលុបចោល។ (មាត្រា370 កថាខណ្ឌទី1 ចំណុច ខ)

# [យោង]ការផ្អាកនិងការលុបចោល ការអនុវត្តដោយបង្ខំ

ដោយឡែក ពុំមានសេចក្ដីថា ឲ្យតែដាក់ពាក្យបណ្ដឹង ឬពាក្យសុំទាំងអស់នោះ ជាធម្មតានីតិវិធីនៃការអនុវត្តដោយបង្ខំនឹងត្រូវបានផ្អាកមួយរយៈនោះទេ។

ដើម្បីផ្អាកនីតិវិធីមួយរយៈរហូតដល់ចេញលទ្ធផល ក្រៅពីដាក់ពាក្យបណ្ដឹង ឬពាក្យសុំតវ៉ា ចាំបាច់ត្រូវធ្វើពាក្យសុំផ្អាកការអនុវត្តចំពោះតុលាការទទួលបណ្ដឹងទៀត ។

(មាត្រា367 មាត្រា369និងមាត្រា370 កថាខណ្ឌទី2 ចំណុច ក)

# [យោង]ការផ្អាកនិងការលុបចោលការអនុវត្តដោយបង្ខំ

តុលាការត្រូវបានកំណត់ថា「អាចបង្គាប់ឲ្យផ្អាកការអនុវត្តដោយបង្ខំបាន」ក្នុងករណីមានពាក្យ「សុំផ្អាកការអនុវត្ត」ហើយក្នុងករណីមូលហេតុនៃឧបាស្រ័យអាចនឹងទទួលស្គាល់បាន។ (មាត្រា367 កថាខណ្ឌទី1 ជាអាទ៍)

ទោះបីជាក្នុងករណីនេះក៏ដោយ ការណ៍ដែលបង្គាប់ឲ្យផ្អាកការអនុវត្ត គឺជាការវិនិច្ឆ័យបដិសេធនូវអានុភាពអនុវត្តនៃសាលក្រម ឬសាលដីកាស្ថាពរដែលនេះជាករណីលើកលែង ពុំមែនដាច់ខាតត្រូវតែបង្គាប់ឲ្យផ្អាកនោះឡើយ។

ក្នុងនាមជាតុលាការ ត្រូវធ្វើការវិនិច្ឆ័យដោយយកចិត្តទុកដាក់ជាទីបំផុត។

# ការផ្អាកការអនុវត្តដោយ ការដាក់ពាក្យបណ្តឹង




សាលក្រមស្ថាពរទទួលស្គាល់ការទាមទារ (1ម៉ឺនដុល្លារអាមេរិក)

# ការផ្អាកការអនុវត្តដោយ
# ការដាក់ពាក្យបណ្តឹង




សាលក្រមស្ថាពរទទួលស្គាល់ការទាមទារ(1ម៉ឺនដុល្លារអាមេរិក)

# ការផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្តឹង

ដូចបានពន្យល់កន្លងមក  អាចនឹងមានកូនបំណុលទុច្ចរិតដាក់ពាក្យបណ្តឹងដោយគ្មានមូលហេតុ ហើយថែមទាំងដាក់ពាក្យសុំផ្អាកការអនុវត្ត ដោយមានបំណងដើម្បីតែរួចផុតពីការអនុវត្តដោយបង្ខំតែប៉ុណ្ណោះ ។

បណ្តឹងប្រភេទនេះ គឺជាការប្រើសិទ្ធិខុសទំនង ចាកឆ្ងាយពីគោលគំនិតនៃប្រព័ន្ធច្បាប់នីមួយៗនោះ ហេតុដូច្នេះ ពុំមានអ្វីដែលអាចឲ្យទទួលស្គាល់បានឡើយ។

ប្រសិនបើត្រូវផ្អាកការអនុវត្តដោយបង្ខំរហូតដល់ករណីបំពានសិទ្ធិប្រភេទនេះ  នោះនឹងក្លាយជាការរារាំងការសម្រេចនូវសិទ្ធិរបស់ភាគីដែលបានទទួលសាលក្រម ឬសាលដីកាទទួលស្គាល់ការទាមទារដែលបានចូលជាស្ថាពរ (អាចអនុវត្តដោយបង្ខំបាន)។

# ការផ្អាកការអនុវត្តដោយការដាក់ពាក្យបណ្តឹង

តុលាការដែលបានទទួលពាក្យសុំផ្អាកការអនុវត្តប្រភេទនេះ ពុំតម្រូវឲ្យបង្គាប់ឲ្យផ្អាកការអនុវត្តទេ ដូច្នេះត្រូវលើកពាក្យសុំនោះចោល ។

ទោះជាយ៉ាងណាក្តី ត្រូវផ្អាកការអនុវត្តដោយបង្ខំជាករណីលើកលែង ដែលកម្រិតតែបណ្តឹងនីមួយៗនោះមានមូលហេតុត្រឹមត្រូវ ។

※ស្តីពីការផ្អាកការអនុវត្តដោយបណ្តឹងជំនុំជម្រះសាជាថ្មី(មាត្រា366 កថាខណ្ឌទី1 ចំណុច ក)សូមមើលឯកសារ(ការជំនុំជម្រះសាជាថ្មី)នៃសិក្ខាសាលានាខែមករា ឆ្នាំ2017។

https://www.jica.go.jp/project/english/cambodia/014/materials/index.html





# សូមអរគុណ។


**International Cooperation Department**
**Research and Training Institute**
**Ministry of Justice of Japan**

**4th Floor, Osaka Nakanoshima National Government Building,**
**1-1-60 Fukushima, Fukushima-ku, Osaka City 553-0003**
**Phone: 81-6-4796-2153 Fax: 81-4796-2157**
**E-mail: icdmoj@i.moj.go.jp**